# អារម្ភកថា

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.) បានរៀបចំផែនការយុទ្ធសាស្ត្រ៥ឆ្នាំ ២០១៩-២០១៨ នេះឡើង ផ្អែកតាមស្ថានភាពសិទ្ធិកុមារបច្ចុប្បន្ននៅកម្ពុជា គោលនយោបាយជាតិ អន្តរជាតិ ផែនការយុទ្ធសាស្ត្រ៣ឆ្នាំ ២០១១-២០១៣ និងស្របតាមអនុសាសន៍នៃរបាយការណ៍សេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិសម្រាប់ប្រទេសកម្ពុជា។

ផែនការយុទ្ធសាស្ត្រឆ្នាំ២០១៩-២០១៨ ក៏បានឆ្លុះបញ្ចាំងពីការរួមចំណែក និងការតភ្ជាប់ទៅការអនុវត្តគោលនយោបាយ និងផែនការជាតិ រួមទាំងយុទ្ធសាស្ត្រចតុកោណស្តីពីកំណើន និងគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ។

ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រនេះ បានផ្តល់ឱកាសឲ្យមានការពិភាក្សា កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូល្អជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធផ្សេងទៀត ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធ្វើយ៉ាងណាឲ្យផែនការនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអាចដាក់ឲ្យអនុវត្តបាន។ ផែនការយុទ្ធសាស្ត្រនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការ ដោះស្រាយបញ្ហាប្រឈមដែលនៅសេសសល់ចំពោះការអនុវត្តសិទ្ធិកុមារនៅកម្ពុជា។

ខ្ញុំមានក្តីសង្ឃឹមមោះមុតថា ក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍ នឹងបន្តការគាំទ្រ និងធ្វើកិច្ចសហប្រតិបត្តិការឲ្យកាន់តែជិតស្និទ្ធ ក្នុងការចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ២០១៩-២០១៨ របស់ ក.ជ.ក. ដើម្បីជាផលប្រយោជន៍របស់កុមារក្នុងប្រទេសកម្ពុជា និងរក្សាការពារធនធានឲ្យបានល្អប្រសើរ។

# មាតិកា


**អារម្ភកថា**....... i

**មាតិកា**....... ii

**អក្សរកាត់**....... iv

**១. គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការលើកកម្ពស់សិទ្ធិកុមារ** ១

១.១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា....... ១

១.២ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣....... ១

១.៣ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា....... ១

១.៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨)....... ២

១.៥ យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ២០១១-២០១៥....... ២

**២. ការវិភាគស្ថានភាព**....... ៣

**៣. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**....... ៧

៣.១ ដំណើរការកសាងផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ....... ៧

៣.២ វឌ្ឍនភាពនៃផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ឆ្នាំ ២០១១-២០១៣....... ៨

៣.៣ ការវិភាគចំណុចខ្លាំង បញ្ហាប្រឈម ឱកាស និងឧបសគ្គ....... ១០

៣.៣.១ ចំណុចខ្លាំង....... ១០

៣.៣.២ បញ្ហាប្រឈម....... ១១

៣.៣.៣ ឱកាស....... ១១

៣.៣.៤ ឧបសគ្គ....... ១២

**៤. ផែនការយុទ្ធសាស្ត្រ ២០១៤-២០១៨**....... ១២

៤.១ ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ....... ១២

៤.២ គោលដៅយុទ្ធសាស្ត្រ....... ១២

៤.២.១ គោលដៅយុទ្ធសាស្ត្រទី១ ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងរបាយការណ៍ស្តីពីសិទ្ធិកុមារ....... ១៣

៤.២.២ គោលដៅយុទ្ធសាស្ត្រទី២ ពង្រឹងយន្តការការពារកុមារ........................................................... ១៥
៤.២.៣ គោលដៅយុទ្ធសាស្ត្រទី៣ លើកកម្ពស់ការយល់ដឹងសិទ្ធិកុមារ និងទាក់ទាញមតិគាំទ្រ........................ ១៧
៤.២.៤ គោលដៅយុទ្ធសាស្ត្រទី៤ បង្កើនសមត្ថភាពស្ថាប័ន និងភាពជាដៃគូ............................................ ២០
៤.៣ ការអនុវត្តយុទ្ធសាស្ត្រ.................................................................................................... ២២
៤.៤ ការពិនិត្យតាមដាន និងវាយតម្លៃ........................................................................................ ២៣
៤.៥ សូចនាករនៃការពិនិត្យតាមដាន និងវាយតម្លៃ......................................................................... ២៥
**ការងារដែលបានដកស្រង់**........................................................................................... ៣៧
**ឧបសម្ព័ន្ធ ក សមាជិកភាព រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច**............................................... ៣៨
**ឧបសម្ព័ន្ធ ខ ការវិភាគចំណុចខ្លាំង បញ្ហាប្រឈម ឱកាស និងឧបសគ្គ**......................... ៤១

# អក្សរកាត់

| | |
|---|---|
| ACWC | គណៈកម្មាធិការអាស៊ានសម្រាប់លើកកម្ពស់ និងការការពារសិទ្ធិស្ត្រី និងកុមារ |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| AIDS | ជំងឺអេដស៍ |
| ARV | ឱសថប្រឆាំងនឹងមេរោគអេដស៍ |
| CNCC | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| CRC | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| CMDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| HIV | មេរោគអេដស៍ |
| IT | បច្ចេកវិទ្យាព័ត៌មាន |
| MDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoI | ក្រសួងមហាផ្ទៃ |
| MoJ | ក្រសួងយុត្តិធម៌ |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoT | ក្រសួងទេសចរណ៍ |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SP | ផែនការយុទ្ធសាស្ត្រ |
| SWOT | ចំណុចខ្លាំង បញ្ហាប្រឈម ឱកាស និងឧបសគ្គ |
| UN | អង្គការសហប្រជាជាតិ |
| UNCRC | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ |

# ១.   គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការលើកកម្ពស់សិទ្ធិកុមារ

## ១.១   រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤៨ចែងថា រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ  ជាពិសេសសិទ្ធិមានជីវិតរស់នៅ  សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយណា ដែលអាចធ្វើឲ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឲ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។

កុមារទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា  ទទួលបានសិទ្ធិជាមូលដ្ឋាន  ដោយគ្មានការរើសអើងពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា នយោបាយ ឬទស្សនៈផ្សេងៗ ជាតិ ជាតិពន្ធ ឬកំណើតសង្គម ទ្រព្យសម្បត្តិ ពិការភាព ស្ថានភាពពីកំណើត ឬស្ថានភាពផ្សេងៗទៀតរបស់កុមារ ឬមាតាបិតា។

## ១.២   យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ជាមគ្គុទេសក៍ច្បាស់លាស់សម្រាប់តម្រែតម្រង់សកម្មភាពរបស់គ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងគោលដៅបន្ត និងពង្រឹងកិច្ចអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់រយៈពេលវែងសំដៅជំរុញកំណើនសេដ្ឋកិច្ច បន្តបង្កើតការងារ បែងចែកផលនៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌   និងធានាឲ្យបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ   និងការគ្រប់គ្រងធនធានគ្រប់ប្រភេទ។

សមាសភាគទាំង៤ នៃយុទ្ធសាស្ត្រចតុកោណគឺ ១.ការលើកស្ទួយវិស័យកសិកម្ម ២.ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត   ៣.ការអភិវឌ្ឍវិស័យឯកជននិងការងារ   និង៤.ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស។ ទន្ទឹមនេះ អភិបាលកិច្ចល្អ គឺជាចំណុចស្នូលនៃយុទ្ធសាស្ត្រចតុកោណ។

យុទ្ធសាស្ត្រចតុកោណ   ជំរុញការអភិវឌ្ឍចក្ខុវិស័យរបស់ប្រទេសកម្ពុជាគ្រប់ជ្រុងជ្រោយដែលធ្វើឲ្យប្រសើរឡើងនូវសិទ្ធិកុមារ។ នៅក្នុងចតុកោណទី៤ មានមុំទី១ ការពង្រឹង និងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស និងមុំទី២ ការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ  ដែលជាមូលដ្ឋានធានាដល់ការលើកកម្ពស់សិទ្ធិកុមារ  អភិវឌ្ឍន៍ធនធានមនុស្ស  និងសុខុមាលភាពសង្គម។

## ១.៣   គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

នៅឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើសេចក្តីប្រកាសសហស្សវត្សរ៍ និងប្តេជ្ញាអនុវត្តឲ្យបានសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍(គ.អ.ស)  ត្រឹមឆ្នាំ២០១៥។  ផ្អែកតាមស្ថានភាពជាក់ស្តែង រាជរដ្ឋាភិបាលបានបន្ថែមគោលដៅទី៩ គឺ ការបោសសម្អាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការជួយសង្គ្រោះជនរងគ្រោះលើគោលដៅចំនួន៨ នៃ គ.អ.ស. មូលហេតុដោយសារតែសង្គ្រាមកាលពីជាងពីរទសវត្សរ៍មុន បានបន្សល់ទុកផ្ទៃដីជាច្រើនមានគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។

រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ស្ដីពីការអភិវឌ្ឍជាតិពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលនឹងរៀបចំការវាយតម្លៃដ៏ទូលំទូលាយនៃការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាក្នុងឆ្នាំ២០១៥។

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលពាក់ព័ន្ធជាពិសេសទៅនឹងកុមារ ត្រូវបានកំណត់ដូចខាងក្រោម៖

គោលដៅទី១ ការលុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ

គោលដៅទី២ សម្រេចឲ្យបានសកលកម្មការអប់រំបឋមសិក្សា

គោលដៅទី៣ លើកកម្ពស់សមភាពយេនឌ័រ

គោលដៅទី៤ កាត់បន្ថយមរណភាពកុមារ

គោលដៅទី៥ លើកកម្ពស់សុខភាពមាតា

គោលដៅទី៦ ប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជំងឺអេដស៍ គ្រុនចាញ់ និងជំងឺផ្សេងៗទៀត

គោលដៅទី៩ ការបោសសម្អាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការជួយសង្គ្រោះជនរងគ្រោះ

## ១.៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨)

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (ផ.យ.អ.ជ) គឺជាផែនទីចង្អុលបង្ហាញផ្លូវសម្រាប់អនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។ សូចនាករម៉ាទ្រិចសេដ្ឋកិច្ចឆ្លុះបញ្ចាំងឲ្យឃើញនូវគោលបំណងការពារសមិទ្ធផលចម្បងកន្លងមករបស់ ផ.យ.អ.ជ ដែលរួមមានការសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចិរភាពក្នុងអត្រាយ៉ាងហោចណាស់ប្រមាណ ៧% ជាមធ្យមក្នុង១ឆ្នាំ និងកាត់បន្ថយអត្រានៃភាពក្រីក្រលើសពី ១% ក្នុង១ឆ្នាំ។ ចំណុចដែលពាក់ព័ន្ធជាពិសេសទៅនឹងកុមារ ត្រូវបានកំណត់ដូចខាងក្រោម៖

- សុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម
- សមាហរណកម្មកម្ពុជាឲ្យកាន់តែស៊ីជម្រៅនៅក្នុងតំបន់ និងពិភពលោក
- កំណែទម្រង់ដីធ្លី និងបោសសម្អាតមីន និងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម
- ការពង្រឹងវិស័យឯកជន និងការជម្រុញការវិនិយោគ និងធុរកិច្ច
- ពង្រឹងនិងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្របច្ចេកទេស ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស
- លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ
- អភិវឌ្ឍប្រព័ន្ធសុវត្ថិភាពសង្គម

## ១.៥ យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ២០១១-២០១៥

យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ២០១១-២០១៥ សង្ឃឹមថាប្រជាជនកម្ពុជាទាំងអស់ ជាពិសេសជនក្រីក្រ និងជនងាយរងគ្រោះ នឹងទទួលបាននូវអត្ថប្រយោជន៍ពីសំណាញ់សុវត្ថិភាពសង្គម និងសន្តិសុខសង្គមកាន់តែប្រសើរឡើង ដែលជាផ្នែកសំខាន់មួយនៃប្រព័ន្ធ

ដ៏មានប្រសិទ្ធភាព សមស្រប និងមាននិរន្តរភាព។ គោលបំណងសំខាន់នៃផែនការយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ គឺជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា ត្រូវបានគាំពារឲ្យបានប្រសើរឡើងពាក់ព័ន្ធនឹងភាពក្រីក្ររ៉ាំរ៉ៃ និងភាពអត់ឃ្លាន វិបត្តិ ភាពខ្វះខាត និងមូលហេតុសង្គម និងអត្ថប្រយោជន៍ពីការវិនិយោគលើមូលធនមនុស្ស។ យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ មានគោលដៅ៥ ដែលពាក់ព័ន្ធជាពិសេសទៅនឹងកុមារ រួមមានៈ

- ជនក្រីក្រ និងជនងាយរងគ្រោះទទួលបានការឧបត្ថម្ភ ដែលរួមមាន ស្បៀង អនាម័យ ទឹក និងជម្រក។ល។ ដើម្បីបំពេញតម្រូវការរបស់ពួកគាត់ ក្នុងពេលវេលាមានគ្រោះអាសន្ន និងវិបត្តិ
- ជនក្រីក្រ កុមារ និងមាតាងាយរងគ្រោះ ទទួលបានផលប្រយោជន៍ពីសំណាញ់សុវត្ថិភាពសង្គម ដើម្បីកាត់បន្ថយភាពក្រីក្រ និងអសន្តិសុខស្បៀង និងពង្រឹងការអភិវឌ្ឍមូលធនមនុស្ស តាមរយៈការបង្កើនគុណភាពអាហារូបត្ថម្ភ សុខភាពមាតា និងកុមារ ការលើកកម្ពស់ការអប់រំ និងការលុបបំបាត់ពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរ។
- ជនក្រីក្រ និងងាយរងគ្រោះដែលពេលវ័យធ្វើការងារ ទទួលផលប្រយោជន៍ពីកាលានុវត្តភាពការងារ ដើម្បីធានាឲ្យមានប្រាក់ចំណូល ស្បៀង និងឲ្យមានការងារធ្វើ ព្រមទាំងរួមក្នុងការកសាងធនធានរូបវន្ត និងធនធានហេដ្ឋារចនាសម្ព័ន្ធសង្គមដែលមាននិរន្តរភាព។
- ជនក្រីក្រ និងងាយរងគ្រោះទទួលបានការថែរក្សាសុខភាពប្រកបដោយប្រសិទ្ធភាពនិងមានគុណភាព ជាពិសេសមានការគាំពារផ្នែកហិរញ្ញវត្ថុពេលមានជំងឺ។
- ក្រុមជនងាយរងគ្រោះពិសេស រួមមាន ក្មេងកំព្រា ចាស់ជរា ស្ត្រីជាមេគ្រួសារ ជនពិការ ជនផ្ទុកមេរោគអេដស៍ ឬអ្នកជំងឺរបេង។ល។ ទទួលបានការគាំទ្រជាប្រាក់ចំណូល សម្ភារៈ និងចិត្តសាស្ត្រសង្គម ព្រមទាំងការថែទាំសង្គមគ្រប់គ្រាន់។

## ២. ការវិភាគស្ថានភាព

ប្រទេសកម្ពុជាមានប្រជាជនវ័យក្មេង ដែលភាគច្រើននៅតំបន់ជនបទ។ ប្រទេសកម្ពុជាមានប្រជាជនសរុបចំនួន ១៤.៦៧៦.៥៩១នាក់ ក្នុងចំណោមនោះ ៧.៥៥៥.០៨៣នាក់ ស្មើនឹង៥១.៤៧% ជាស្ត្រី។ ក្នុងចំណោមចំនួនប្រជាជនទាំងអស់ ប្រជាជនចំនួន ១១.៥៣០.៣៧៨នាក់ ស្មើនឹង៧៨.៦% រស់នៅតំបន់ជនបទ និង ៣.១៤៦.២១៣នាក់ ស្មើនឹង២១.៤% រស់នៅទីប្រជុំជន។ កុមារអាយុក្រោម១៨ឆ្នាំ សរុបមានចំនួន ៥.២១៧.៧៣៣នាក់ ស្មើនឹង៣៥.៥% នៃចំនួនប្រជាជនសរុប។ កុមារអាយុពី 0-៦ឆ្នាំ មានចំនួន ១.៩២២.៩៦៩នាក់ ស្មើនឹង ១៣.១%។[1]

### ២.១. ការរស់រានមានជីវិតរបស់កុមារ

រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាពក្នុងការកាត់បន្ថយអត្រាមរណភាពមាតា និងទារក តាមរយៈការពង្រឹងបន្ថែមគុណភាព និងការពង្រីកសេវាសុខភាព។ ជាលទ្ធផល កម្ពុជាសម្រេចបានវឌ្ឍនភាពគួរឲ្យមោទនៈ ដោយអត្រាមរណៈរបស់មាតាបានថយចុះពី ៤៧១ នៅឆ្នាំ២០០៥ មកត្រឹម ២០៦ នៅឆ្នាំ ២០១០ ក្នុង១០០.០០០កំណើតរស់។ អត្រាមរណៈរបស់ទារកអាយុក្រោម៥ឆ្នាំ បានថយចុះពី៦៥ នៅ

[1]អង្កេតចន្លោះជំរឿន នៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣ វិទ្យាស្ថានជាតិស្ថិតិ

ឆ្នាំ២០០៥ មកត្រឹម ៤៥ នៅឆ្នាំ២០១០ ក្នុង១.០០០កំណើតរស់។ អត្រាមរណៈរបស់ទារក បានថយចុះពី៨៣ នៅឆ្នាំ២០០៥ មកត្រឹម ៥៤ នៅឆ្នាំ២០១០ ក្នុង១.០០០កំណើតរស់។[២] ទោះបីជាភាពល្អប្រសើរទាំងនេះមានលក្ខណៈគួរឲ្យកត់សម្គាល់យ៉ាងណាក៏ដោយ អត្រាមរណៈរបស់មាតា និងទារក គឺនៅតែខ្ពស់បើប្រៀបធៀបទៅនឹងប្រទេសផ្សេងៗនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។[៣]

បញ្ហាអាទិភាពផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា គឺបង្កើនចំនួនកុមារដែលត្រូវគាំពារ តាមរយៈការចាក់ថ្នាំបង្ការរោគ(vaccination)។ នៅឆ្នាំ២០១៣ កុមារអាយុក្រោម១ឆ្នាំ ជាង ៩០% បានទទួលវ៉ាក់សាំងបង្ការជំងឺ ៨ មុខ រួមមានវ៉ាក់សាំងបង្ការៈ ១-ជំងឺរបេង ២-ជំងឺគ្រុនស្វិតដៃជើង ៣-ជំងឺតេតាណូស ៤-ជំងឺខាន់ស្លាក់ ៥-ជំងឺក្អកមាន់ ៦-ជំងឺកញ្ជ្រឹល ៧-ជំងឺរលាកថ្លើមប្រភេទបេ និង៨-បង្ការជំងឺរលាកស្បូត (Hib)។ កុមារអាយុក្រោម១ឆ្នាំ ចំនួន ៣២៦.៣៣៤ នាក់ ស្មើនឹង ៩៥% នៃកុមារចំណុច បានទទួលវ៉ាក់សាំង ៣លើក ដើម្បីបង្ការជំងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស និងរលាកថ្លើមប្រភេទបេ។ អត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងបង្ការជំងឺកញ្ជ្រឹល ដល់កុមារអាយុក្រោម១ឆ្នាំ សម្រេចបាន ៩៣.៣៧% នៃចំនួនចំណុច។ នៅកម្ពុជា ជំងឺគ្រុនស្វិតដៃជើងត្រូវបានលុបបំបាត់ទាំងស្រុងតាំងពីឆ្នាំ២០០០ និងជំងឺកញ្ជ្រឹលនៅឆ្នាំ២០១២។[៤]

ការកាត់បន្ថយការរីករាលដាលនៃមេរោគអេដស៍បានទទួលជោគជ័យគួរជាទីមោទនៈ។ ការរីករាលដាលនៃមេរោគអេដស៍ក្នុងចំណោមប្រជាជនអាយុពី ១៥ ទៅ ៤៩ បានថយចុះ២% នៅឆ្នាំ១៩៩៨ មក ០.៩% នៅឆ្នាំ២០០៦ និងបន្តធ្លាក់ចុះរហូតដល់ ០.៧% នៅឆ្នាំ២០១២។ កុមារកម្ពុជាដែលមានផ្ទុកមេរោគអេដស៍ស្ទើរតែទាំងអស់បានទទួលឱសថប្រឆាំងនឹងមេរោគអេដស៍ ដោយមានកុមារផ្ទុកមេរោគអេដស៍ចំនួន៤.៥៩៤នាក់ បានទទួលឱសថប្រឆាំងនឹងមេរោគអេដស៍នៅឆ្នាំ២០១១[៥]។ ទោះបីជាយ៉ាងណាក៏ដោយ កុមារ និងគ្រួសារដែលប៉ះពាល់ដោយមេរោគអេដស៍ និងជំងឺអេដស៍នៅតែប្រឈមមុខនឹងបញ្ហាការមាក់ងាយ លក្ខខណ្ឌសេដ្ឋកិច្ចសង្គមស្ថិតនៅទាប និងបានបង្កើនអត្រាពលកម្មកុមារ និងអត្រាអវត្តមានពីសាលារៀន។[៦]

កុមារកម្ពុជាប្រឈមនឹងឧបសគ្គនៃការរស់រានជីវិតផ្សេងៗជាច្រើនទៀត។ កង្វះខាតអាហារូបត្ថម្ភរបស់កុមារ នៅមានកម្រិតខ្ពស់នៅឡើយ។ ភាពក្រិនរបស់កុមារបានធ្លាក់ចុះត្រឹមតែ៣% ប៉ុណ្ណោះ ពោលគឺពី ៤៣% មក ៤០% រវាងឆ្នាំ២០០៥ និងឆ្នាំ២០១០ ដែលជាការធ្លាក់ចុះតិចតួចបំផុតក្នុងរយៈពេល៥ឆ្នាំ។ កុមារខ្វះទំងន់មិនមានបង្ហាញពីវឌ្ឍនភាពឡើយ។ ដោយឡែកកុមារស្គមស្គាំង បានកើនឡើងរវាងឆ្នាំ ២០០៥ និងឆ្នាំ២០១០។ ប្រេវ៉ាឡង់ស្ត្រី និងកុមារដែលខ្វះគ្រាប់ឈាមក្រហម មិនមានការប្រែប្រួលទេក្នុងរវាងឆ្នាំ២០០៥ និងឆ្នាំ២០១០។[៧] ស្លាប់ដោយគ្រោះថ្នាក់ផ្សេងៗ ដូចជា គ្រោះថ្នាក់ចរាចរណ៍ និងការលង់ទឹក គឺគំរាមគំហែងខ្លាំងដល់កុមារក្នុងប្រទេសកម្ពុជា។ កុមារ និងយុវជនប្រឈមឧបសគ្គពីបញ្ហាសង្គមផងដែរ ដូចជា គ្រឿងញៀន គ្រឿងស្រវឹង និងបារី។

---

[២] របាយការណ៍វឌ្ឍភាពប្រចាំឆ្នាំ២០១៣ ស្តីពីការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ក្រសួងផែនការ ឆ្នាំ២០១៤

[៣] យូនីសេហ្វ ២០១៣

[៤] ក្រសួងសុខាភិបាល ២០១៣

[៥] ក្រសួងសុខាភិបាល ២០១៣

[៦] អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ២០១២

[៧] របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៣ ស្តីពីការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ក្រសួងផែនការ ឆ្នាំ២០១៤

## ២.២. ការអប់រំ

រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាពដល់កុមារ និងយុវជនក្នុងការសម្រេចបានការអប់រំដំបូងជាសកលសម្រាប់កុមារទាំងអស់គ្នាតាមរយៈការអប់រំមូលដ្ឋាន៩ឆ្នាំ។ កិច្ចខិតខំប្រឹងប្រែងដើម្បីសម្រេចបានគោលដៅនេះរួមមាន ការបង្កើនចំនួនសាលារៀន ការធ្វើឲ្យប្រសើរគុណភាពអប់រំតាមរយៈការលើកកម្ពស់សាលាកុមារមេត្រី និងការលើកទឹកចិត្តឲ្យកុមារគ្រប់រូបបានចុះឈ្មោះចូលរៀនទាំងអស់គ្នា។ យោងតាមលទ្ធផល អត្រារួមចូលរៀនថ្មីមានកុមារចំនួន១៣៧.២% ត្រូវបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា និងអត្រាពិតចូលរៀនថ្មីនៅសាលាបឋមសិក្សា មានចំនួន៩៨.២%។[៨] អត្រាចូលរៀនគឺទាបជាង និងអត្រាបោះបង់ការសិក្សាខ្ពស់ជាងសម្រាប់កុមារនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលជាពិសេសកុមារី។[៩]

ការស្វែងយល់ពីឧបសគ្គដែលប្រឈមដោយសិស្សជនជាតិដើមភាគតិច ថ្មីៗនេះរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតការអប់រំពីរភាសា និងបានផ្តល់អាហារូបករណ៍មានការកើនឡើង ដែលបច្ចុប្បន្នមានកុមារជនជាតិដើមភាគតិចចំនួន៥៤% បានទទួលអាហារូបករណ៍។[១០] ទាំងនេះជាលទ្ធផលសំខាន់ៗ ប៉ុន្តែសម្រាប់ការអប់រំបឋមសិក្សានៅក្នុងខេត្តដែលមានកុមារជនជាតិដើមភាគតិចច្រើន តែអត្រាចុះឈ្មោះចូលរៀន នៅមានកម្រិតទាបជាងតំបន់ដទៃទៀត នៃប្រទេសកម្ពុជា។[១១]

រាជរដ្ឋាភិបាល បានបង្កើតគោលនយោបាយជាតិស្តីពីការអប់រំកុមារពិការ និងកំពុងធ្វើការបណ្តុះបណ្តាលគ្រូបង្រៀន និងលើកកម្ពស់ការអប់រំបញ្ចូលគ្នាបន្ថែមទៀត។ ទោះបីជាយ៉ាងណា កាបញ្ចូលសិស្សពិការនៅតែទាបជាងចំណុចដៅ ដោយសារបញ្ហាប្រឈមនៃការអនុវត្តកម្មវិធីការអប់រំបញ្ចូលគ្នា។[១២]

## ២.៣ ការការពារកុមារ

រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាព ក្នុងការធ្វើឲ្យប្រសើរនូវប្រព័ន្ធការការពារកុមារក្នុងប្រទេសកម្ពុជា។ ប្រព័ន្ធការការពារកុមារដែលមានប្រសិទ្ធភាពបំផុត គឺប្រព័ន្ធច្បាប់ គោលនយោបាយ កម្មវិធី និងសេវានានា ដែលត្រូវបានរៀបចំដើម្បីការពារកុមារពីអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពាន។ ដើម្បីស្វែងយល់កាន់តែច្បាស់ពីក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងការការពារកុមារ នាពេលបច្ចុប្បន្ន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានរៀបចំកម្រងឯកសារច្បាប់ និងគោលនយោបាយសម្រាប់កុមារ និងការវិភាគភាពខ្វះចន្លោះនៃច្បាប់ការការពារកុមារ ហើយផ្អែកតាមកិច្ចការទាំងនេះ ក.ជ.ក. កំពុងផ្តួចផ្តើមរៀបចំច្បាប់ស្តីពីការការពារកុមារ និងយុទ្ធសាស្ត្រស្វែងរកការគាំទ្រគោលនយោបាយពីក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ។

[៨] របាយការណ៍បូកសរុប ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១២-២០១៣

[៩] កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ២០១១

[១០] ក្រសួងអប់រំ យុវជន និងកីឡា ២០១៣

[១១] កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ២០១១

[១២] ក្រសួងអប់រំ យុវជន និងកីឡា ២០១៣

រាជរដ្ឋាភិបាលបានបន្តពង្រឹងច្បាប់ និងគោលនយោបាយការការពារកុមារ។ ច្បាប់ និងគោលនយោបាយទាំងនោះរួមមាន ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស បានដាក់ឲ្យអនុវត្តចាប់ពីឆ្នាំ២០១៤ ប៉ុន្តែមិនបានទូលំទូលាយទេ ចំពោះប្រទេសណាមានបំណងធ្វើការស្មុំកូនអន្តរប្រទេសត្រូវចុះកិច្ចព្រមព្រៀងកំណត់ចំនួនទីភ្នាក់ងារដែលត្រូវធ្វើសហប្រតិបត្តិការស្មុំកូនអន្តរប្រទេសនៅព្រះរាជាណាចក្រកម្ពុជាជាមុនសិន។ ជាមួយគ្នានេះដែរ យន្តការ និងនីតិវិធីស្មុំកូនក្នុងស្រុក បាននិងកំពុងរៀបចំដើម្បីធានាបញ្ហាស្មុំកូនពុំមានការជួញដូរ ឬរំលោភបំពានដោយប្រការណាមួយ។ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីសិទ្ធិជនពិការត្រូវបានអនុម័តនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ និងបានក្លាយជារដ្ឋភាគី នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២។ សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជនបាននិងកំពុងពិនិត្យកែសម្រួល ហើយនឹងត្រូវបញ្ជូនបន្តដើម្បីស្នើសុំការអនុម័ត។ ភាពកាន់តែល្អប្រសើរនៅក្នុងក្របខ័ណ្ឌច្បាប់ការការពារកុមារគឺកំពុងបន្តកើតមាន ប៉ុន្តែប្រព័ន្ធការការពារកុមារនៅតែមានកម្រិតនៅឡើយ។

ជាការឆ្លើយតបពាក់ព័ន្ធនឹងប្រព័ន្ធសុខុមាលភាពកុមារ ចំពោះកុមារដែលមានភាពងាយរងគ្រោះ ឬការរំលោភបំពាន ជាទូទៅកុមារទាំងនោះត្រូវបានគេយកទៅដាក់នៅក្នុងមណ្ឌល មុននឹងបញ្ជូនពួកគេទៅគ្រួសារ ឬសហគមន៍វិញ។ ដើម្បីបង្កើនគុណភាពនៃការថែទាំកុមារនៅតាមមណ្ឌល រាជរដ្ឋាភិបាលបានធ្វើការកែលម្អមណ្ឌល ហើយមណ្ឌលកុមារណាដែលមិនបានអនុវត្តតាមបទដ្ឋានអប្បបរមា និងបទប្បញ្ញតិនានាត្រូវបានកាត់បន្ថយ។ រាជរដ្ឋាភិបាលផ្តល់អាទិភាពដល់កម្មវិធីផ្តល់ការគាំទ្រដល់គ្រួសារក្រីក្រក្នុងការថែទាំកុមារក្នុងក្របខ័ណ្ឌគ្រួសារ កម្មវិធីថែទាំកុមារតាមសហគមន៍ ព្រមជាមួយនោះការបង្រួបបង្រួមគ្រួសារ និងការស្វែងរកគ្រួសារល្អឲ្យកុមារត្រូវបានអនុវត្តតាមនីតិវិធីស្មុំកូនក្នុងប្រទេស និងអន្តរប្រទេសស្របតាមច្បាប់ជាធរមាន។ ជាមួយគ្នានេះក៏មានដៃគូអភិវឌ្ឍផ្តល់សេវាគាំពារកុមារជាច្រើន ប៉ុន្តែពុំទាន់បានអនុវត្តតាមគោលការណ៍បានទាំងស្រុង ហើយសេវាទាំងនោះពុំទាន់មានលក្ខណៈជាប្រព័ន្ធនៅឡើយ។

ក្នុងទិសដៅដោះស្រាយបញ្ហាខាងលើនេះ រាជរដ្ឋាភិបាលបានជំរុញការអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ បទដ្ឋានអប្បរមាសម្រាប់ការថែទាំកុមារនៅក្នុងមណ្ឌល បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ និងការធ្វើប្រតិភូកម្មមុខងារលើវិស័យសុខុមាលភាពកុមារតាមប្រព័ន្ធវិមជ្ឈការទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះ ការធ្វើអធិការកិច្ចជាកិច្ចការចាំបាច់ក្នុងការពិនិត្យវាយតម្លៃ ក្នុងករណីការថែទាំកុមារ ពុំស្របតាមបទដ្ឋានអប្បបរមា និងគោលការណ៍ បទប្បញ្ញត្តិនានា ដែលបាននិងកំពុងអនុវត្តជាធរមាន។ បទដ្ឋាននិងគោលការណ៍ណែនាំសម្រាប់ការថែទាំ ការគាំទ្រ និងការការពារកុមារកំព្រា និងកុមារងាយរងគ្រោះ បានបង្កើត និងកំពុងផ្សព្វផ្សាយ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះជាការពង្រឹងការឆ្លើយតប ទោះជាយ៉ាងណាបច្ចុប្បន្ននៅតែមានមណ្ឌលចំនួន ២១៩ ដែលផ្តល់ការថែទាំ ក្នុងនោះមាន ២២ជាមណ្ឌលរដ្ឋ។[១៣]

កុមារ នៅតែប្រឈមនឹងភាពងាយរងគ្រោះផ្សេងៗមួយចំនួនទៀតផងដែរ។ ប្រទេសកម្ពុជាតាមការប៉ាន់ប្រមាណមានកុមារចំនួន ១.៥០០.០០០នាក់ ចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូល។[១៤] រាជរដ្ឋាភិបាល បានផ្តល់អាទិភាពលើការដកហូតកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងបានសហការ

[១៣] ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

[១៤] អង្កេតសុខភាពប្រជាសាស្ត្រ ២០១០ ក្រសួងសុខាភិបាល

ជាមួយអង្គការសង្គមស៊ីវិលដើម្បីផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើឲ្យល្អប្រសើរលក្ខខណ្ឌការងារ។ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដកហូត និងទប់ស្កាត់ និងការពារកុមារបានចំនួន ១.១៩២នាក់ (៥៦០នាក់ ជាកុមារី) ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងបានបញ្ជូនពួកគេឲ្យទទួលបានការអប់រំក្រៅប្រព័ន្ធ ឬបណ្តុះបណ្តាលវិជ្ជាជីវៈ។ ទោះបីជាយ៉ាងណា ដោយសារភាពក្រីក្រនៅក្នុងប្រទេសកម្ពុជានៅមានកម្រិតខ្ពស់ កុមារនឹងបន្តធ្លាក់ចូលក្នុងសកម្មភាពរកប្រាក់ចំណូល។

រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តខ្លាំងក្លា ដើម្បីការពារកុមារពីការជួញដូរមនុស្ស ការជួញដូរកម្លាំងពលកម្ម និងការកេងប្រវ័ញ្ចផ្លូវភេទ។ គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបការជួញដូរមនុស្ស ការរត់ពន្ធការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ បានដោះស្រាយបញ្ហានេះយ៉ាងសកម្ម។ ក្នុងឆ្នាំ២០១២ ជនរងគ្រោះចំនួន ៥៥៨នាក់ ត្រូវបានជួយសង្គ្រោះ ដែលក្នុងចំណោមនោះមានជនរងគ្រោះចំនួន ១៥៤នាក់ មានអាយុក្រោម១៨ឆ្នាំ (៨៣នាក់ ក្រោមអាយុ១៥ឆ្នាំ)។[១៥] ដើម្បីប្រយុទ្ធប្រឆាំងនឹងការរំលោភបំពានផ្លូវភេទលើកុមារ ក្រសួងទេសចរណ៍បានខិតខំប្រឹងប្រែងផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការលើកកម្ពស់សុវត្ថិភាពដើម្បីបង្ការទេសចរណ៍ផ្លូវភេទលើកុមារផងដែរ។[១៦]

អំពើហិង្សាលើកុមារជាកង្វល់មួយផងដែរ។ មិនមានស្ថិតិច្បាស់លាស់ស្តីពីស្ថានភាពនេះនៅឡើយទេ។ ទោះបីជាយ៉ាងណា ថ្មីៗនេះការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារត្រូវបានធ្វើឡើងដោយក្រសួងកិច្ចការនារី សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយទទួលបានការឧបត្ថម្ភពីមូលនិធិសហប្រជាជាតិដើម្បីកុមារ។ របកគំហើញទាំងនោះនឹងត្រូវផ្សព្វផ្សាយនៅឆ្នាំ២០១៤ ដែលនឹងជួយឲ្យយល់កាន់តែច្បាស់ពីបញ្ហាប្រឈមនានា។

## ៣. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសមាត្រា ៤៤ រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារតាមអនុក្រឹត្យលេខ៨៣ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៥ បន្ទាប់មកនៅឆ្នាំ១៩៩៩ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានកែសម្រួលតាមអនុក្រឹត្យលេខ៥៦ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៩ ហើយនៅចុងឆ្នាំ២០០៩ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានកែសម្រួលតាមព្រះរាជក្រឹត្យលេខនស/រតក/ ១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ដែលសរសេរអក្សរកាត់ថា (ក.ជ.ក.) ដើម្បីជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការងារទាក់ទងនឹងការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព និងការរួមចំណែករបស់កុមារ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានពង្រីករចនាសម្ព័ន្ធចំនួន ២៤ រាជធានី ខេត្ត និងក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ន ចំនួន៩។ តួនាទី និងការទទួលខុសត្រូវរបស់ ក.ជ.ក. មាននៅក្នុងឧបសម្ព័ន្ធ ក។

### ៣.១ ដំណើការកសាងផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ដំណើការកសាងផែនការយុទ្ធសាស្ត្ររបស់ ក.ជ.ក. ត្រូវបានអនុវត្តក្នុងរយៈពេល ៦ខែ (ខែមីនាដល់ខែកញ្ញា ឆ្នាំ២០១៣)។ ដំណើរការនេះត្រូវបានដឹកនាំដោយផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុនៃ

[១៥] ក្រសួងមហាផ្ទៃ ២០១៣

[១៦] ក្រសួងទេសចរណ៍ ២០១៣

អគ្គលេខាធិការដ្ឋាន ក.ជ.ក. ដោយមានការជួយគាំទ្រពីទីប្រឹក្សាបច្ចេកទេស និងមន្ត្រីជំនាញមកពីមូលនិធិសហប្រជាជាតិដើម្បីកុមារ អង្គការផ្លែនអន្តរជាតិ និងអង្គការសង្គ្រោះកុមារ។

ដំណើរការកសាងផែនការយុទ្ធសាស្ត្រនេះ រួមមានជំហានដូចខាងក្រោម៖

**១.ការពិនិត្យឯកសារ:** ជំហានដំបូងនៅក្នុងដំណើរការកសាងផែនការយុទ្ធសាស្ត្រ គឺពិនិត្យផែនការយុទ្ធសាស្ត្រ ឆ្នាំ២០១១-២០១៣ ឡើងវិញ ដើម្បីកំណត់ភាពជោគជ័យ និងបញ្ហាប្រឈមក្នុងការអនុវត្តផែនការនេះ។ ដំណើរការនេះរួមមានការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រចាស់ របាយការណ៍ប្រចាំឆ្នាំ និងឯកសាររបស់ ក.ជ.ក. ផ្សេងៗទៀត។ របកគំហើញនៃការពិនិត្យផែនការយុទ្ធសាស្ត្រ ២០១១-២០១៣ ត្រូវបានធ្វើរបាយការណ៍ជូន ក.ជ.ក. ហើយត្រូវបានសង្ខេបនៅក្នុងផ្នែកវឌ្ឍនភាពនៃផែនការយុទ្ធសាស្ត្ររបស់ ក.ជ.ក. ២០១១-២០១៣ ខាងក្រោម។

**២. ការធ្វើសម្ភាសអ្នកពាក់ព័ន្ធ:** ជំហានបន្ទាប់ក្នុងការកសាងផែនការយុទ្ធសាស្ត្រ គឺធ្វើសម្ភាសអ្នកពាក់ព័ន្ធសំខាន់ៗ។ អ្នកពាក់ព័ន្ធសំខាន់ៗដែលបានធ្វើសម្ភាស រួមមាន តំណាងក្រសួង និងមន្ទីរពាក់ព័ន្ធសំខាន់ៗ ដូចជា ក្រសួងយុត្តិធម៌ មហាផ្ទៃ ទេសចរណ៍ ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អប់រំ យុវជន និងកីឡា កិច្ចការនារី និង ក.ជ.ក. រាជធានី ខេត្តចំនួន៧ តំណាងមកពីមូលនិធិសហប្រជាជាតិដើម្បីកុមារ អង្គការផ្លែនអន្តរជាតិ អង្គការសង្គ្រោះកុមារ អង្គការទស្សនៈពិភពលោក សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ ចលនាយុវជននិងកុមារកម្ពុជាដើម្បីសិទ្ធិកុមារ តំណាងយុវជន មន្ត្រីនៃអគ្គលេខាធិការដ្ឋាន ក.ជ.ក. ផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ ផ្នែកការការពារកុមារ និងពិនិត្យតាមដាន ផ្នែកអប់រំ ផ្សព្វផ្សាយ និងអភិវឌ្ឍធនធានមនុស្ស និងទីប្រឹក្សាបច្ចេកទេស របស់ ក.ជ.ក.។

**៣.ការវិភាគ:** របកគំហើញពីការពិនិត្យផែនការយុទ្ធសាស្ត្រ ២០១១-២០១៣ ការសម្ភាសអ្នកពាក់ព័ន្ធសំខាន់ៗត្រូវបានវិភាគ។ ដំណើការនេះរួមមានការពិនិត្យស្ថានភាពដោយប្រើប្រាស់ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងឧបសគ្គ បានកំណត់ភាពជោគជ័យ បញ្ហាប្រឈម និងឱកាសរបស់ ក.ជ.ក. សម្រាប់អនាគត។ ផ្អែកតាមការវិភាគនេះ យុទ្ធសាស្ត្រ គោលបំណង និងសកម្មភាពត្រូវបានរៀបចំដោយផ្អែកលើលទ្ធផលសម្រេចបានរបស់ផែនការចាស់ និងដោះស្រាយបញ្ហាប្រឈមដែលនៅសេសសល់។ ការវិភាគចំណុចខ្លាំង បញ្ហាប្រឈម ឱកាស និងឧបសគ្គ ត្រូវបានសង្ខេបនៅខាងក្រោម និងមាននៅក្នុងឧបសម្ព័ន្ធ ខ។

### ៣.២ វឌ្ឍនភាពនៃផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ឆ្នាំ ២០១១-២០១៣

តួនាទី និងការទទួលខុសត្រូវរបស់ ក.ជ.ក. ដូចដែលបានរៀបរាប់ខាងលើ គឺមានសារៈសំខាន់ចំពោះការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារប្រកបដោយប្រសិទ្ធភាព។ ផែនការយុទ្ធសាស្ត្រ២០១១-២០១៣ ត្រូវបានរៀបចំដើម្បីកសាងជំនាញ សមត្ថភាព និងធនធានរបស់ ក.ជ.ក. កែលម្អការពិនិត្យតាមដាន និងការធ្វើរបាយការណ៍ស្តីពីអនុសញ្ញាស្តីពីសិទ្ធិកុមារជូនរាជរដ្ឋាភិបាល និងគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ បង្កើនចំណេះដឹងស្ថានភាពសិទ្ធិកុមារ និងលើកកម្ពស់យុទ្ធសាស្ត្រ ច្បាប់ និងគោលនយោបាយសម្រាប់កុមារ។ ក.ជ.ក. សម្រេចបានវឌ្ឍនភាពសំខាន់ៗឆ្ពោះទៅរកការសម្រេចគោលដៅ

គោលបំណង និងសកម្មភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ ២០១១-២០១៣។[១៧] ប្រាកដណាស់ វឌ្ឍនភាពនេះមានសារៈសំខាន់ណាស់ ហើយភាពជោគជ័យនៃសកម្មភាពទាំងនេះជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ជាអាទិភាពនាពេលអនាគត ដើម្បីអនុវត្តសិទ្ធិកុមារបន្ថែមទៀត។

ក.ជ.ក. បានបង្កើនប្រសិទ្ធភាពរបស់ខ្លួនតាមរយៈការបង្កើនសមត្ថភាពមន្ត្រី និងតាមរយៈការពង្រីករចនាសម្ព័ន្ធរបស់ខ្លួន ដែលអនុញ្ញាតឲ្យ ក.ជ.ក. អនុវត្តការងារកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល។ វគ្គបណ្តុះបណ្តាលសំខាន់ៗត្រូវបានរៀបចំឲ្យមានទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ បានធ្វើការវិភាគតួនាទីភារកិច្ចរបស់ខ្លួន និងបានដាក់ចេញអនុសាសន៍ឲ្យអនុវត្តបន្ថែមទៀត។ ការពង្រឹងតួនាទី និងប្រភពធនធានបន្ថែមនៅថ្នាក់ក្រោមជាតិ ជាតម្រូវការចាំបាច់ ដើម្បីបង្កើនការទទួលខុសត្រូវរបស់ពួកគេ។ ក.ជ.ក. បានរៀបចំផែនទីបង្ហាញផ្លូវសម្រាប់រៀបចំផែនការជាតិដើម្បីកុមារ។ ផែនការជាតិដើម្បីកុមារនេះ នឹងក្លាយជាផែនការ៥ឆ្នាំ ដែលនឹងបម្រើដើម្បីសម្របសម្រួលផែនការតាមវិស័យទាំងអស់ និងកំណត់ភាពខ្វះចន្លោះ ក្នុងការអនុវត្តសិទ្ធិកុមារក្នុងប្រទេសកម្ពុជា។ ផែនការនេះនឹងផ្តល់ជាមូលដ្ឋានសម្រាប់ការពិនិត្យតាមដានសិទ្ធិកុមាររបស់ ក.ជ.ក. និងផ្តល់យោបល់លើស្ថានភាពសិទ្ធិកុមារ ក្នុងប្រទេសកម្ពុជា។

ក.ជ.ក. មិនទាន់ទទួលបានជោគជ័យលើការអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃដែលមានលក្ខណៈជាប្រព័ន្ធឲ្យមានប្រសិទ្ធភាពនៅឡើយទេ។ ប្រព័ន្ធនេះនឹងក្លាយជាកិច្ចការសំខាន់ ដើម្បីពិនិត្យតាមដានស្ថានភាពសិទ្ធិកុមារ និងការអនុវត្តផែនការជាតិដើម្បីកុមារឲ្យមានប្រសិទ្ធភាព។ សូចនាករសិទ្ធិកុមារបានរៀបចំដោយសហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិ។ ជំហានបន្ទាប់ គឺគិតគូរឡើងវិញពីប្រព័ន្ធការពិនិត្យតាមដាន និងការប្រមូលទិន្នន័យថ្មីៗ និងផ្លាស់ប្តូរការរៀបចំ និងការអនុវត្តប្រព័ន្ធឲ្យបានទូលំទូលាយដែលមានព័ត៌មានគ្រប់គ្រាន់សម្រេចតាមសេចក្តីត្រូវការ។

ក.ជ.ក. សម្រេចបានជោគជ័យក្នុងការផ្តល់របាយការណ៍ស្តីពីស្ថានភាពសិទ្ធិកុមារជូនរាជរដ្ឋាភិបាល និងគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ។ របាយការណ៍ទាំងនេះបានកើតឡើងដោយប្រើប្រាស់វិធីដោះស្រាយបន្ទាន់ (ad-hoc approach) និងអាចកែលម្អការប្រមូលទិន្នន័យ និងការវិភាគស្ថានភាពសិទ្ធិកុមារកាន់តែល្អប្រសើរថែមទៀត រួមមាន ការកំណត់ភាពខ្វះចន្លោះចំណេះដឹង និងការផ្តួចផ្តើមសិក្សាដើម្បីដោះស្រាយភាពខ្វះចន្លោះទាំងនេះ។

ក.ជ.ក. បានផ្សព្វផ្សាយរបកគំហើញនៃសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារ និងបានអនុវត្តការងារដើម្បីលើកកម្ពស់ចំណេះដឹងសិទ្ធិកុមារ តាមរយៈព្រឹត្តិការណ៍ទិវាកុមារអន្តរជាតិ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ និងទិវាកុមារកម្ពុជា សិក្ខាសាលាផ្សព្វផ្សាយ វគ្គបណ្តុះបណ្តាល កិច្ចពិភាក្សា កម្មវិធីសិល្បៈ វីដេអូអប់រំខ្លី សម្ភារសម្រាប់ផ្សព្វផ្សាយ។ល។ កិច្ចការទាំងនេះបានទទួលជោគជ័យ និងអាចធ្វើឲ្យប្រសើរបន្ថែមទៀត តាមរយៈការអភិវឌ្ឍជំនាញឲ្យកាន់តែល្អ និងកំណត់អ្នកចូលរួមឲ្យកាន់តែទូលំទូលាយ។ ក.ជ.ក. បានរៀបចំព្រឹត្តិបត្រស្ថានភាពកុមារបានចំនួន២លេខ។

ក.ជ.ក. បានលើកកម្ពស់ការចូលរួមរបស់កុមារ តាមរយៈការបង្កើតគោលការណ៍ណែនាំស្តីពីការអនុវត្តការចូលរួមរបស់កុមារ និងការជំរុញឲ្យមានសម្លេងកុមារនៅក្នុងសកម្មភាពផ្សេងៗ។ ក.ជ.ក.

[១៧] របាយការណ៍ពិនិត្យផែនការយុទ្ធសាស្ត្រ ក.ជ.ក. ២០១១-២០១៣ មាននៅអគ្គលេខាធិការដ្ឋាន ក.ជ.ក.

បានរៀបចំសៀវភៅសិក្សាស្តីពីសិទ្ធិកុមារសម្រាប់មន្រ្តីរបស់ខ្លួន និងអាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់វគ្គបណ្តុះបណ្តាលនានាចំពោះអ្នកមានវិជ្ជាជីវៈដទៃទៀត។

ក.ជ.ក. បានទទួលការយល់ដឹងកាន់តែច្បាស់ នៃភាពខ្វះចន្លោះពាក់ព័ន្ធច្បាប់ការការពារកុមារ តាមរយៈការរៀបចំកម្រងឯកសារច្បាប់ការការពារកុមារ និងការវិភាគភាពខ្វះចន្លោះនៃច្បាប់និងគោលនយោបាយ។ ជំហានបន្ទាប់គឺរៀបចំ និងអនុវត្តយុទ្ធសាស្រ្តទាក់ទាញមតិគាំទ្រដើម្បីរៀបចំច្បាប់ការការពារកុមារ។ កិច្ចការនេះនឹងរៀបចំដោយសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន ដូចជាក្រសួងយុត្តិធម៌ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មហាផ្ទៃ និងក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ។ល។

ក.ជ.ក. បានបង្កើនកិច្ចសហប្រតិបត្តិការជាតិ តំបន់ អាស៊ាន ដើម្បីឲ្យមានតំណាងសិទ្ធិកុមារ និងសិទ្ធិស្ត្រីបានចូលជាសមាជិកគណៈកម្មាធិការអាស៊ានសម្រាប់លើកកម្ពស់ និងការពារសិទ្ធិស្ត្រីនិងកុមារ។ កម្ពុជាបានទទួលរៀបចំសន្និសីទថ្នាក់តំបន់ស្តីពីផលប៉ះពាល់លើស្ត្រី និងកុមារដោយសារការបម្រែបម្រួលអាកាសធាតុ ជាមួយគ្នានេះប្រតិភូកុមារបានទៅចូលរួមកិច្ចប្រជុំតំបន់ និងអន្តរជាតិជាច្រើនលើកស្របគ្នានិងទំនាក់ទំនងរវាងគណៈកម្មាធិការ ក្រុមការងារ និងក្រុមចលនាកុមារបានបង្កើតឡើងជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់សិទ្ធិកុមារនៅកម្ពុជា។ ក.ជ.ក បានរៀបចំផែនទីនៃគណៈកម្មាធិការ និងក្រុមការងារដែលធ្វើការងារពាក់ព័ន្ធនឹងកុមារ ហើយនឹងផ្តល់ជាមូលដ្ឋានសម្រាប់សហប្រតិបត្តិការកាន់តែល្អប្រសើរ ដើម្បីលើកកម្ពស់សិទ្ធិកុមារ។

ក.ជ.ក. បាននិងកំពុងរៀបចំការសិក្សាស្រាវជ្រាវការងារថវិកាសម្រាប់ការផ្តល់សេវាសង្គមដោយផ្តោតលើវិស័យកុមារ ដើម្បីពិនិត្យលើដំណើរការរៀបចំផែនការយុទ្ធសាស្រ្ត ក្របខ័ណ្ឌការងារស្របតាមកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការសិក្សាស្រាវជ្រាវ គឺផ្តោតលើវិស័យចម្បងៗចំនួន៣ រួមមាន អប់រំ អាហារូបត្ថម្ភ និងកិច្ចការពារកុមារ។

ក.ជ.ក. សម្រេចបានការអភិវឌ្ឍសំខាន់ៗ ក្នុងការសម្រេចអាណត្តិរបស់ខ្លួន និងធ្វើជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការលើកកម្ពស់សិទ្ធិកុមារបន្ថែមទៀត តាមរយៈការពិនិត្យតាមដាន ការធ្វើរបាយការណ៍ និងការស្វែងរកការគាំទ្រច្បាប់ និងគោលនយោបាយ និងការលើកកម្ពស់ការចូលរួមរបស់កុមារក្នុង ៥ឆ្នាំបន្ទាប់។

### ៣.៣ ការវិភាគចំណុចខ្លាំង បញ្ហាប្រឈម ឱកាស និងឧបសគ្គ

បន្ទាប់ពីការពិនិត្យសកម្មភាពកម្មវិធី និងសម្ភាសជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងឧបសគ្គ បានបង្ហាញដូចខាងក្រោម៖

#### ៣.៣.១ ចំណុចខ្លាំង

- ក.ជ.ក. បានអនុវត្តផ្នែកសំខាន់ៗនៃផែនការយុទ្ធសាស្រ្ត ២០១១-២០១៣ ដោយជោគជ័យ តាមរយៈការអភិវឌ្ឍ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ
- ក.ជ.ក. មានរចនាសម្ព័ន្ធច្បាស់លាស់ និងបានពង្រីកដល់ថ្នាក់រាជធានី ខេត្ត និងតាមក្រសួងស្ថាប័ន

- អគ្គលេខាធិការដ្ឋាន ក.ជ.ក. មានក្រុមការងារដែលមានសមត្ថភាពកាន់តែខ្លាំង និងមានតួនាទី និងការទទួលខុសត្រូវកាន់តែច្បាស់លាស់សម្រាប់ផ្នែកនីមួយៗ
- ក.ជ.ក. មានទំនាក់ទំនងរឹងមាំជាមួយក្រសួងដទៃទៀត ដូចជា ក្រសួងអប់រំ យុវជន និងកីឡា យុត្តិធម៌ ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ទេសចរណ៍ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា វិទ្យាស្ថានជាតិស្ថិតិ។ល។ ហើយក៏មានទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការដ៏រឹងមាំផងដែរ ជាមួយសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការពាក់ព័ន្ធនឹងសិទ្ធិកុមារ
- ក.ជ.ក. បានបញ្ចប់ការវាយតម្លៃ ការវិភាគ និងធ្វើផែនការសកម្មភាព ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការងារនាពេលអនាគត រួមមាន ការវិភាគតួនាទីភារកិច្ច ការសិក្សាថវិកាសង្គម គោលការណ៍ណែនាំស្តីពីការអនុវត្តការចូលរួមរបស់កុមារ សៀវភៅសិក្សាស្តីពីសិទ្ធិកុមារ ផែនទីបង្ហាញផ្លូវដើម្បីរៀបចំផែនការជាតិដើម្បីកុមារ សូចនាករសំខាន់ៗសម្រាប់ការពិនិត្យតាមដានអនុសញ្ញាស្តីពីសិទ្ធិកុមារ ផែនទីបង្ហាញនៃក្រុមការងារ និងមូលដ្ឋានទិន្នន័យសិទ្ធិកុមារ ការវិភាគភាពខ្វះចន្លោះនៃច្បាប់ការការពារកុមារ និងកម្រងឯកសារច្បាប់ និងគោលនយោបាយពាក់ព័ន្ធនឹងកុមារ។

### ៣.៣.២ បញ្ហាប្រឈម

- ក.ជ.ក.បានអនុវត្តផ្នែកសំខាន់ៗនៃសកម្មភាពដែលបានគ្រោងទុកក្នុងផែនការយុទ្ធសាស្ត្រ ២០១១-២០១៣ និងបានរៀបចំរបាយការណ៍សកម្មភាពប្រចាំឆ្នាំ ប៉ុន្តែរបាយការណ៍ប្រចាំឆ្នាំ ពុំទាន់បានឆ្លើយតបទៅនឹងសូចនាករដូចដែលបានកំណត់
- ក.ជ.ក. មិនទាន់មានប្រព័ន្ធការងារពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ការប្រមូល និងគ្រប់គ្រងទិន្នន័យ ដែលប្រការនេះធ្វើឲ្យសមត្ថភាពក្នុងការពិនិត្យតាមដានស្ថានភាពសិទ្ធិកុមារក្នុងប្រទេសកម្ពុជានៅមានកម្រិតនៅឡើយ
- ក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ន និង ក.ជ.ក. រាជធានី ខេត្ត មិនមានថវិកាជាតិសម្រាប់បម្រើឲ្យសកម្មភាព ដូចដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ
- ទាមទារឲ្យមានការអភិវឌ្ឍន៍សមត្ថភាពជំនាញបន្ថែមទាក់ទងនឹងច្បាប់ ព័ត៌មានវិទ្យា ការពិនិត្យតាមដាននិងវាយតម្លៃ នីតិវិធីនៃការសរសេររបាយការណ៍ក្នុងទម្រង់ជាតិ អន្តរជាតិជាភាសាខ្មែរនិងអង់គ្លេស និង ជំនាញគ្រប់គ្រងនិងទំនាក់ទំនង
- ក.ជ.ក. ថ្នាក់រាជធានី ខេត្ត មិនទាន់យល់ច្បាស់លាស់ពីតួនាទីភារកិច្ចរបស់ខ្លួន ដើម្បីធានាការគាំទ្រ និងការសហការពីអាជ្ញាធរថ្នាក់ក្រោមជាតិ និងដើម្បីអនុវត្តការងារទៅតាមអាណត្តិរបស់ ក.ជ.ក.។

### ៣.៣.៣ ឱកាស

- ឧបករណ៍វាយតម្លៃ ការវិភាគ និងការធ្វើផែនការបានបញ្ចប់ ផ្អែកតាមលទ្ធផលផែនការយុទ្ធសាស្ត្រ ២០១១-២០១៣ ដែលផ្តល់ជាមូលដ្ឋាន និងឧបករណ៍សម្រាប់សកម្មភាពជាយុទ្ធសាស្ត្រ ដែលទទួលបានជោគជ័យនៅឆ្នាំ២០១៤-២០១៨ ជាមួយនឹងប្រភពធនធានផ្សេងៗគ្នាទាំងនេះ ក.ជ.ក. បានបញ្ចប់ការសិក្សាស្រាវជ្រាវពីប្រវត្តិសំខាន់ៗ និងឧបករណ៍

ការរៀបចំផែនការដើម្បី អនុវត្តយុទ្ធសាស្ត្ររបស់ខ្លួន នៅក្នុងផែនការយុទ្ធសាស្ត្រ ២០១៤-២០១៨។

៣.៣.៤ ឱបសគ្គ

- មិនទាន់មានប្រភពធនធានពីខាងក្រៅ សម្រាប់យុទ្ធសាស្ត្រអាទិភាពទាំងអស់របស់ ក.ជ.ក.
- ភាពសុខុដុមនីយកម្មអាណត្តិ តួនាទី និងការទទួលខុសត្រូវរបស់ ក.ជ.ក. ជាមួយនឹងគណៈកម្មាធិការ និងរចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាលផ្សេងៗទៀតនៅមានកម្រិតនៅឡើយ។

# ៤ ផែនការយុទ្ធសាស្ត្រ ២០១៤-២០១៨

## ៤.១ ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

### ចក្ខុវិស័យ

កុមារក្នុងប្រទេសកម្ពុជា ទទួលបាននូវសិទ្ធិជាមូលដ្ឋាន ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដូចជា រស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ និងសម្រេចបាននូវសក្តានុពលដ៏ពិតប្រាកដរបស់ពួកគេ។

### បេសកកម្ម

បង្កើតបរិយាកាសឲ្យសិទ្ធិរបស់កុមារទាំងអស់ បានលើកកម្ពស់ និងការពារ តាមរយៈច្បាប់ គោលនយោបាយ និងកម្មវិធីដើម្បីធានាឧត្តមប្រយោជន៍កុមារ។

### គុណតម្លៃ

- ធ្វើសហប្រតិបត្តិការ
- គណនេយ្យភាព
- សមធម៌

## ៤.២ គោលដៅយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រនេះមានគោលដៅយុទ្ធសាស្ត្រអាទិភាពចំនួន ០៤ សម្រាប់រយៈពេល ៥ឆ្នាំបន្ទាប់ទៀត ដោយផ្អែកលើតួនាទី និងការទទួលខុសត្រូវរបស់ ក.ជ.ក.។ លទ្ធផលការងារទាំងអស់នេះគឺផ្អែកតាមអាណត្តិរបស់ ក.ជ.ក. ហើយយុទ្ធសាស្ត្របង្កើតឡើងដោយផ្អែកលើភាពជោគជ័យរបស់ ក.ជ.ក. និងត្រូវរៀបចំឡើងដើម្បីដោះស្រាយបញ្ហាប្រឈមរបស់ខ្លួន។ លទ្ធផលជាយុទ្ធសាស្ត្រមានដូចជា៖

គោលដៅយុទ្ធសាស្ត្រទី១៖ ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងរបាយការណ៍ស្តីពីស្ថានភាពកុមារ

គោលដៅយុទ្ធសាស្ត្រទី២៖ ពង្រឹងយន្តការការពារកុមារ

គោលដៅយុទ្ធសាស្ត្រទី៣៖ លើកកម្ពស់ការយល់ដឹងនិងការទាក់ទាញមតិគាំទ្រ

គោលដៅយុទ្ធសាស្ត្រទី៤៖ បង្កើនសមត្ថភាពស្ថាប័ន និងភាពជាដៃគូ

បញ្ហាអន្តរវិស័យត្រូវបានកំណត់អត្តសញ្ញាណ ដើម្បីបញ្ជ្រាបចូលទៅក្នុងផែនការយុទ្ធសាស្ត្រនេះ។ បញ្ហាទាំងអស់នេះ រួមមាន យេនឌ័រ ការចូលរួមរបស់កុមារ ពិការភាព និងជាតិពន្ធុ។

នៅក្នុងគោលដៅយុទ្ធសាស្ត្រនីមួយៗ យុទ្ធសាស្ត្រមួយមានគោលបំណង និងសកម្មភាពត្រូវបានបង្កើតឡើង ដើម្បីនាំឲ្យ ក.ជ.ក. ឆ្ពោះទៅមុខក្នុងការសម្រេចបានចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃរបស់ខ្លួនសម្រាប់រយៈពេល ៥ឆ្នាំបន្ទាប់។

### ៤.២.១ គោលដៅយុទ្ធសាស្ត្រទី១ : ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងរបាយការណ៍ស្តីពីសិទ្ធិកុមារ

**គោលបំណង :** ធ្វើឲ្យប្រសើរឡើងនូវការអនុវត្តសិទ្ធិកុមារ តាមរយៈការពិនិត្យតាមដានស្ថានភាពសិទ្ធិកុមារដ៏មានប្រសិទ្ធភាពនៅក្នុងប្រទេសកម្ពុជាដើម្បីផ្តល់របាយការណ៍ជូនរាជរដ្ឋាភិបាល គណៈកម្មាធិការសិទ្ធិកុមារ និងស្ថាប័នសិទ្ធិមនុស្សនៃ អ.ស.ប ទាន់ពេលវេលា និងប្រកបដោយគុណភាព។

**លទ្ធផល១.១ : ក្របខ័ណ្ឌការងារពិនិត្យតាមដាន និងការប្រមូលទិន្នន័យ ៖** *បានបង្កើតក្របខ័ណ្ឌការងារពិនិត្យតាមដាននិងការប្រមូលទិន្នន័យទូលំទូលាយ និងប្រព័ន្ធពិនិត្យតាមដាន ដែលបញ្ចូលទិន្នន័យពីគ្រប់វិស័យទាក់ទិនទៅនឹងការអនុវត្តសិទ្ធិកុមារ។*

***ទិន្នផល ១.១.១ : ប្រព័ន្ធប្រមូលទិន្នន័យ និងការពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ ត្រូវបានដាក់ឲ្យអនុវត្ត ។***

**សកម្មភាព ១.១.១.១** : កំណត់តម្រូវការទិន្នន័យសំខាន់ៗ ដើម្បីតាមដានស្ថានភាពសិទ្ធិកុមារ ផ្អែកលើសូចនាករសិទ្ធិកុមាររបស់ ក.ជ.ក. និងការវិភាគអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប បន្ថែមទៀត ដើម្បីកំណត់ និងប្រមូលទិន្នន័យពីបណ្តាក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល វិទ្យាស្ថានស្រាវជ្រាវ សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ។

**សកម្មភាព ១.១.១.២** : វាយតម្លៃភាពរីកចម្រើននៃប្រព័ន្ធគ្រប់គ្រងទិន្នន័យបច្ចុប្បន្ន ហើយផ្អែកលើការវិភាគនេះ ទិន្នន័យសំខាន់ៗត្រូវបានកំណត់សម្រាប់បង្កើត និងអនុវត្តប្រព័ន្ធប្រមូលទិន្នន័យថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**សកម្មភាព ១.១.១.៣** : រៀបចំសៀវភៅណែនាំស្តីពីនីតិវិធី ដែលកំណត់ពីទិន្នន័យសម្រាប់ប្រមូលនិងវិភាគ ក៏ដូចជាពេលវេលាសម្រាប់ប្រមូលនិងវិភាគ។

***ទិន្នផល ១.១.២ : ប្រព័ន្ធប្រមូលទិន្នន័យពីវិស័យនានា ត្រូវបានធ្វើឲ្យប្រសើរឡើងនូវគុណភាព សុខដុមនីយកម្ម និងស្របគ្នាជាមួយបទដ្ឋានជាតិ និងអន្តរជាតិ។***

**សកម្មភាព ១.១.២.១** : សហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិ ប្រព័ន្ធព័ត៌មានកម្ពុជា (CamInfo) ប្រព័ន្ធមូលដ្ឋានទិន្នន័យឃុំ សង្កាត់ និងប្រព័ន្ធទិន្នន័យផ្សេងៗទៀត ដើម្បីពិនិត្យឡើងវិញពីតម្រូវការយន្តការនៃការប្រមូលទិន្នន័យ និងកំណត់ភាពខ្វះខាតនៅក្នុងប្រភពដែលអាចរកបាន។

**សកម្មភាព ១.១.២.២** : កំណត់ប្រភពទិន្នន័យដែលចាំបាច់ ដែលមិនអាចស្វែងរកបានក្នុងពេលបច្ចុប្បន្ន ដើម្បីពិនិត្យតាមដានអនុសញ្ញាស្តីពីសិទ្ធិកុមារ។

**សកម្មភាព ១.១.២.៣** : បង្កើតយន្តការប្រមូលទិន្នន័យសម្រាប់ប្រភពទិន្នន័យទាំងអស់ និងបញ្ចូលសូចនាករបន្ថែមទៅក្នុងប្រព័ន្ធទិន្នន័យជាតិ។

***ទិន្នផល ១.១.៣ : សមត្ថភាពរបស់សមាជិក ក.ជ.ក. ថ្នាក់ក្រោមជាតិ ទាក់ទិននឹងការពិនិត្យតាមដានស្ថានភាពសិទ្ធិកុមារ ត្រូវបានពង្រឹង។***

**សកម្មភាព ១.១.៣.១** : កំណត់អាទិភាពសម្រាប់ធ្វើការពិនិត្យតាមដានបញ្ហាបន្ទាន់ និងការចូលរួមរបស់កុមារនៅក្នុងដំណើរការរបស់រាជរដ្ឋាភិបាល នៅថ្នាក់ក្រោមជាតិ។

**សកម្មភាព ១.១.៣.២** : រៀបចំ និងអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងប្រមូលទិន្នន័យជាទៀងទាត់ ដែលរាយការណ៍ពីថ្នាក់ក្រោមជាតិ។

**លទ្ធផល ១.២ : ការវិភាគទិន្នន័យ និងការរៀបចំរបាយការណ៍៖** *ការវិភាគទិន្នន័យ និងការរៀបចំរបាយការណ៍កាន់តែមានប្រសិទ្ធភាព និងទាន់ពេលវេលា ត្រូវបានបញ្ចប់ ដោយផ្អែកតាមវិស័យសំខាន់ៗដែលពាក់ព័ន្ធទៅនឹងការអនុវត្តសិទ្ធិកុមារ។*

***ទិន្នផល ១.២.១ : ក.ជ.ក. មានសមត្ថភាពវិភាគទិន្នន័យ និងរៀបចំរបាយការណ៍ជាប្រព័ន្ធ ស្តីពីស្ថានភាពសិទ្ធិកុមារនៅប្រទេសកម្ពុជា។***

**សកម្មភាព ១.២.១.១** : បណ្តុះបណ្តាលមន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក. ពីនីតិវិធីប្រមូលទិន្នន័យ ដោយប្រើប្រាស់សៀវភៅណែនាំសម្រាប់ការប្រមូលទិន្នន័យ និងប្រព័ន្ធពិនិត្យតាមដាន។

**សកម្មភាព ១.២.១.២** : ស្វែងរកការគាំទ្របច្ចេកទេសដល់មន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក. ពីការវិភាគទិន្នន័យសម្រាប់ការវិភាគស្ថានភាពកុមារប្រចាំឆ្នាំ។

***ទិន្នផល ១.២.២ : របាយការណ៍វិភាគស្ថានភាពកុមារគ្រប់ជ្រុងជ្រោយត្រូវបានរៀបចំចងក្រងជាទៀងរាល់ឆ្នាំ។***

**សកម្មភាព ១.២.២.១** : ពិនិត្យឡើងវិញ និងវិភាគទិន្នន័យដែលបានប្រមូល តាមរយៈការប្រមូលទិន្នន័យ និងការពិនិត្យតាមដានស្ថានភាពដោយផ្អែកលើអត្ថបទគោលស្តីពីសិទ្ធិកុមារ។

**សកម្មភាព ១.២.២.២:** រៀបចំរបាយការណ៍វិភាគស្ថានភាពសិទ្ធិកុមារប្រចាំឆ្នាំ។

**សកម្មភាព ១.២.២.៣** : កំណត់ភាពខ្វះចន្លោះរបស់ទិន្នន័យដែលអាចរកបាន ដើម្បីបង្កើតរបៀបវារៈស្រាវជ្រាវបន្ថែម។

***ទិន្នផល ១.២.៣ : របាយការណ៍ស្តីពីការអនុវត្តសិទ្ធិកុមារតាមកាលកំណត់នៅឆ្នាំ ២០១៨ ត្រូវបានផ្ញើជូនគណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប ទាន់ពេលវេលា និងប្រកបដោយគុណភាព។***

**សកម្មភាព ១.២.៣.១ :** រៀបចំផែនការធ្វើសេចក្តីព្រាងសរសេររបាយការណ៍ ឆ្នាំ២០១៨ ដើម្បីកំណត់នូវទិន្នន័យខ្វះចន្លោះ និងស្វែងរកព័ត៌មាន ដើម្បីធ្វើឲ្យរបាយការណ៍នេះមានលក្ខណៈពេញលេញ។

**សកម្មភាព ១.២.៣.២ :** រៀបចំរបាយការណ៍ស្តីពីការអនុវត្តសិទ្ធិកុមារ ជូនគណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប នៅឆ្នាំ២០១៨ និង តាមដាននិងទទួលរាល់អនុសាសន៍។

**លទ្ធផល ១.៣ : ការស្រាវជ្រាវ ៖** *ធ្វើឲ្យប្រសើរឡើងការយល់ដឹងពីស្ថានភាពសិទ្ធិកុមារដោយផ្អែកលើភស្តុតាង និងការអនុវត្តប្រកបដោយជោគជ័យ។*

***ទិន្នផល១.៣.១ : ការស្រាវជ្រាវត្រូវបានបញ្ចប់ ហើយធ្វើការចែករំលែកដើម្បីឲ្យការយល់ដឹងពីស្ថានភាពសិទ្ធិកុមារក្នុងប្រទេសកម្ពុជាកាន់តែល្អប្រសើរ។***

**សកម្មភាព១.៣.១.១ :** រៀបចំរបៀបវារៈនៃការស្រាវជ្រាវ ដោយផ្អែកលើភាពខ្វះចន្លោះនៃទិន្នន័យដើម្បីផ្តល់នូវការយល់ដឹងពីស្ថានភាពសិទ្ធិកុមារ។

**សកម្មភាព១.៣.១.២ :** កំណត់ប្រភពធនធានសម្រាប់ការគាំទ្រ ឬភាពជាដៃគូ ដើម្បីបញ្ចប់ការស្រាវជ្រាវទៅលើភាពខ្វះចន្លោះក្នុងវិស័យនានា ដើម្បីឆ្លើយតបទៅនឹងសិទ្ធិកុមារ។

**សកម្មភាព១.៣.១.៣ :** បំពេញ ឬសហការគ្នាលើការស្រាវជ្រាវពីភាពខ្វះចន្លោះតាមវិស័យដែលមានសារៈសំខាន់សម្រាប់កុមារ។

៤.២.២ គោលដៅយុទ្ធសាស្ត្រទី២ : ពង្រឹងយន្តការការពារកុមារ

**គោលបំណង :** បង្កើតផែនការសកម្មភាព ច្បាប់ និងគោលនយោបាយដើម្បីការពារសិទ្ធិកុមារកាន់តែល្អប្រសើរ។

**លទ្ធផល ២.១ : ពិនិត្យឡើងវិញគោលនយោបាយ** *៖ ការធ្វើឲ្យប្រសើរនូវក្របខ័ណ្ឌគោលនយោបាយ ដើម្បីលើកកម្ពស់ការអនុវត្តសិទ្ធិកុមារជាមួយនឹងការបង្កើនថវិកា។*

***ទិន្នផល ២.១.១ : ផែនការជាតិដើម្បីកុមារត្រូវបានបញ្ចប់ និងបង្កើតផែនការយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់សិទ្ធិកុមារ រួមបញ្ចូលកុមារនៅក្នុងស្ថានភាពងាយរងគ្រោះជាពិសេស និងការលើកកម្ពស់ការលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាប្រឆាំងកុមារ។***

**សកម្មភាព ២.១.១.១ :** ពិនិត្យផែនការតាមវិស័យ តាមក្រសួងពាក់ព័ន្ធដែលទាក់ទងនឹងសិទ្ធិកុមារ និងកំណត់ភាពខ្វះចន្លោះ និងធ្វើឲ្យសុខដុមនីយកម្មសកម្មភាព ដើម្បីពង្រឹងការឆ្លើយតបទៅនឹងស្ថាប័នចំពោះការអនុវត្តសិទ្ធិកុមារ។

**សកម្មភាព ២.១.១.២ :** រៀបចំសម្របសម្រួលផែនការជាតិដើម្បីកុមារ ជាមួយកម្មវិធីរបស់អ្នកពាក់ព័ន្ធសំខាន់ៗរួមមាន អាជ្ញាធរពាក់ព័ន្ធ និងសង្គមស៊ីវិលរួមទាំងកុមារ។

**សកម្មភាព ២.១.១.៣ :** បង្កើតប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តផែនការជាតិដើម្បីកុមារ ទាំងការវាយតម្លៃពាក់កណ្តាល ទាំងការវាយតម្លៃបញ្ចប់អាណត្តិ។

***ទិន្នផល ២.១.២ : យុទ្ធសាស្ត្រទាក់ទាញមតិគាំទ្រថវិកាសង្គមផ្តោតលើកុមារត្រូវបានបង្កើត និងអនុវត្ត។***

**សកម្មភាព២.១.២.១ :** ផ្សព្វផ្សាយរបកគំហើញនៃការស្រាវជ្រាវថវិកាសង្គម។

**សកម្មភាព ២.១.២.២ :** បង្កើតក្រុមការងារថវិកាសម្រាប់កុមារ ដើម្បីបង្កើត និងអនុវត្តយុទ្ធសាស្ត្រទាក់ទាញមតិគាំទ្រថវិកាសង្គម ដោយផ្តោតលើសិទ្ធិកុមារ។

**សកម្មភាព ២.១.២.៣ :** ក.ជ.ក. សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍស្តីពីសុខុមាលភាពកុមារ។

**លទ្ធផល ២.២ : របៀបវារៈច្បាប់ស្តីពីការការពារកុមារ និងនីតិវិធីបណ្តឹង៖** *ក្របខ័ណ្ឌច្បាប់ស្តីពីសិទ្ធិកុមារ និងការការពារកុមាររបស់ប្រទេសកម្ពុជាត្រូវបានពង្រឹង។*

***ទិន្នផល ២.២.១ : យុទ្ធសាស្ត្រទាក់ទាញមតិគាំទ្ររបៀបវារៈច្បាប់ដោយភ្ជាប់ជាមួយនឹងអនុសាសន៍ដើម្បីវិសោធនកម្មសម្រាប់សកម្មភាព គោលនយោបាយ និងច្បាប់ថ្មី ត្រូវបានបង្កើត និងបង្ហាញជូនដល់ស្ថាប័នសមស្រប។***

**សកម្មភាព២.២.១.១ :** បង្កើតយុទ្ធសាស្ត្រអាទិភាពសម្រាប់សកម្មភាពគោលនយោបាយ និងច្បាប់ដើម្បីបញ្ចូលសិទ្ធិកុមារ ដោយផ្អែកតាមការវិភាគភាពខ្វះចន្លោះនៃច្បាប់ការការពារកុមារ និងការស្វែងយល់បន្ថែមពីស្ថានភាពបច្ចុប្បន្ន។

**សកម្មភាព២.២.១.២ :** ពិនិត្យឡើងវិញយុទ្ធសាស្ត្រអាទិភាពសម្រាប់សកម្មភាព គោលនយោបាយ និងច្បាប់ ដើម្បីធានាថាពួកគេធានាសិទ្ធិរបស់ប្រជាជនងាយរងគ្រោះជាពិសេស រួមបញ្ចូលកុមារក្នុងការថែទាំជំនួស កុមារនៅមណ្ឌលឃុំខ្លួន កុមារពិការ កុមារបម្លាស់ទី កុមារជនជាតិភាគតិច និងសាសនាភាគតិច ជាពិសេសកុមារងាយរងគ្រោះ។

**សកម្មភាព២.២.១.៣ :** ស្វែងរកឱកាសកិច្ចសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីទាក់ទាញមតិគាំទ្រសម្រាប់ការអនុវត្តគោលនយោបាយ និងច្បាប់ឲ្យបានត្រឹមត្រូវ រួមទាំងពង្រីកបទដ្ឋានអង្គការសុវត្ថិភាពកុមារ ទៅជាបទដ្ឋានសុវត្ថិភាពកុមារគ្រប់វិស័យ/គ្រប់ផ្នែក។

**សកម្មភាព២.២.១.៤ :** ទាក់ទាញមតិគាំទ្រដើម្បីរៀបចំប្រកាស និងអនុក្រឹត្យថ្មី ដើម្បីការការពារកុមារដោយផ្អែកលើយុទ្ធសាស្ត្រអាទិភាពសម្រាប់សកម្មភាព គោលនយោបាយ និងច្បាប់ថ្មី។ សហការជាមួយក្រុមការងារ

ថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រានិងកុមាររងាយរងគ្រោះ ក្រសួងសង្គមកិច្ច អតីតយុទ្ធ និងយុវនីតិសម្បទា និងដៃគូសំខាន់ៗដទៃទៀតក្នុងកិច្ចខិតខំប្រឹងប្រែងនេះ។

***ទិន្នផល ២.២.២ : ប្រព័ន្ធការការពារកុមារថ្នាក់ជាតិ និងយន្តការនីតិវិធីបណ្តឹងរបស់រាជរដ្ឋាភិបាល មានភាពច្បាស់លាស់ និងមានភាពល្អប្រសើរ។***

**សកម្មភាព ២.២.២.១ :** រៀបចំវេទិកាពិភាក្សាជាមួយក្រសួងពាក់ព័ន្ធ ដើម្បីបង្កើតស្ថាប័នសម្របសម្រួលសម្រាប់ការពារកុមារនៅក្នុងប្រទេសកម្ពុជា។

**សកម្មភាព ២.២.២.២ :** ស្វែងរកការគាំទ្រជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីបង្កើតប្រព័ន្ធការពារកុមារដោយកំណត់ពីតួនាទីរបស់ក្រសួងពាក់ព័ន្ធក្នុងការការពារបង្ការ និងផ្តល់សេវានិងស្តារនីតិសម្បទាកុមារ ដោយផ្អែកតាមបទដ្ឋានដែលបានអនុវត្តល្អៗកន្លងមក។

**សកម្មភាព ២.២.២.៣:** សិក្សា និងផ្តល់សច្ចាប័នលើពិធីសារបន្ថែមស្តីពីនីតិវិធីបណ្តឹង។

**សកម្មភាព ២.២.២.៤:** សិក្សាពីនីតិវិធី នៃការបង្កើតយន្តការទទួលពាក្យបណ្តឹងពាក់ព័ន្ធនឹងបញ្ហាកុមារ។

### ៤.២.៣ គោលដៅយុទ្ធសាស្ត្រទី៣ : លើកកម្ពស់ការយល់ដឹង និងទាក់ទាញមតិគាំទ្រ

**គោលបំណង :** បង្កើនចំណេះដឹងសិទ្ធិកុមារដល់ក្រសួង ស្ថាប័ន សង្គមស៊ីវិល សហគមន៍ មាតាបិតា និងកុមារ ដើម្បីធ្វើការរួមគ្នាឲ្យប្រសើរឡើងដើម្បីបំពេញនូវសិទ្ធិ និងការទទួលខុសត្រូវចំពោះកុមារ។

**លទ្ធផល ៣.១ : ការបណ្តុះបណ្តាលសិទ្ធិកុមារ** ៖ *បានបង្កើនសមត្ថភាពអាជ្ញាធរពាក់ព័ន្ធ ដើម្បីអនុវត្តសិទ្ធិកុមារ។*

***ទិន្នផល៣.១.១ : សេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារ និងពិធីសារបន្ថែមត្រូវបានផ្សព្វផ្សាយទូលំទូលាយ។***

**សកម្មភាព៣.១.១.១ :** ផ្សព្វផ្សាយសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារដល់អាជ្ញាធរពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**សកម្មភាព៣.១.១.២ :** ផលិត និងផ្សព្វផ្សាយសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារក្នុងទម្រង់កុមារមេត្រី និងឪពុកម្តាយមេត្រី។

**សកម្មភាព៣.១.១.៣ :** ផ្សព្វផ្សាយពិធីសារបន្ថែមដល់អាជ្ញាធរពាក់ព័ន្ធ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

*ទិន្នផល៣.១.២ : ក្រុមដែលមានវិជ្ជាជីវៈ ដូចជា ចៅក្រម មេធាវី អ្នកអនុវត្តច្បាប់ មន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ គ្រូបង្រៀន បុគ្គលិកសុខាភិបាល អ្នកចិត្តសាស្ត្រ និងអ្នកធ្វើការសង្គម ត្រូវបានពង្រឹងសមត្ថភាពផ្នែកសិទ្ធិកុមារ។*

**សកម្មភាព៣.១.២.១ :** បង្កើតបទដ្ឋានជាតិសម្រាប់បណ្តុះបណ្តាលលើសិទ្ធិកុមារ និងច្បាប់។

**សកម្មភាព៣.១.២.២ :** កសាងភាពជាដៃគូជាមួយក្រសួងពាក់ព័ន្ធ ដើម្បីផ្តល់ការបណ្តុះបណ្តាលដល់អ្នកមានវិជ្ជាជីវៈឲ្យចំគោលដៅ ដើម្បីការពារសិទ្ធិកុមារ រួមទាំងកុមារនៅក្នុងស្ថានភាពងាយរងគ្រោះជាពិសេស និងលើកកម្ពស់ការចូលរួមរបស់កុមារ។

**សកម្មភាព ៣.១.២.៣:** លើកកម្ពស់ និងសម្របសម្រួលក្រសួងនីមួយៗ ធ្វើការផ្សព្វផ្សាយសិទ្ធិកុមារដល់ភ្នាក់ងារសង្គមស៊ីវិល ដែលធ្វើការងារពាក់ព័ន្ធនឹងវិស័យរបស់ស្ថាប័នពួកគេ។

**លទ្ធផល ៣.២ : បង្កើនការយល់ដឹងសិទ្ធិកុមារជាសាធារណៈ៖** សង្គមស៊ីវិល គ្រួសារ និងកុមារ មានការកើនឡើងនូវចំណេះដឹងពីសិទ្ធិកុមារ។

*ទិន្នផល ៣.២.១ : យុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយព្រឹត្តិការណ៍លើកកម្ពស់ចំណេះ ដឹង និងសម្ភារសម្រាប់ផ្សព្វផ្សាយត្រូវបានផលិត ដើម្បីលើកកម្ពស់ ការយល់ដឹងជាសាធារណៈផ្នែកសិទ្ធិកុមារនិងអនុសញ្ញាស្តីពីសិទ្ធិកុមារ*

**សកម្មភាព៣.២.១.១ :** លើកកម្ពស់យុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយជាតិ ដើម្បីផ្សព្វផ្សាយឲ្យទូលំទូលាយដល់កុមារ និងគ្រួសារយល់ដឹងពីអនុសញ្ញាស្តីពីសិទ្ធិកុមារ។

**សកម្មភាព៣.២.១.២ :** ជំរុញឲ្យមានព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹង នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចជា ទិវាកុមារអន្តរជាតិ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ និងផ្សេងៗទៀត។

**សកម្មភាព៣.២.១.៣ :** ផលិត និងចែកចាយសម្ភារសម្រាប់ផ្សព្វផ្សាយ ដូចជា ព្រឹត្តិបត្រព័ត៌មាន ខិតប័ណ្ណ ប័ណ្ណផ្សព្វផ្សាយស្តីពីសិទ្ធិកុមារ និងអនុសញ្ញាសិទ្ធិកុមារ។

**សកម្មភាព៣.២.១.៤ :** បន្តលើកកម្ពស់គេហទំព័ររបស់ ក.ជ.ក.។

**សកម្មភាព៣.២.១.៥ :** ផ្តល់ឱកាសពិភាក្សា និងវិភាគលើបញ្ហាសិទ្ធិកុមារ តាមរយៈវេទិកាសាធារណៈ ដែលមានការចូលរួមពីអង្គការយុវជន សមាគមពាណិជ្ជកម្ម ស្ថាប័នស្រាវជ្រាវ និងពាណិជ្ជកម្ម ដើម្បីលើកកម្ពស់ការយល់ដឹង និងទាក់ទាញការគាំទ្រគោលនយោបាយស្តីពីយន្តការការការពារ។

**លទ្ធផល ៣.៣ : ការចូលរួមរបស់កុមារ៖** បង្កើនការចូលរួមរបស់កុមារក្នុងការធ្វើផែនការ ការអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃគោលនយោបាយ និងកម្មវិធីទាក់ទងនឹងសិទ្ធិកុមារ។

*ទិន្នផល៣.៣.១ : ក.ជ.ក. ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអាជ្ញាធរពាក់ព័ន្ធ ត្រូវបានពង្រឹងសមត្ថភាពស្តីពីគោលការណ៍ណែនាំស្តីពីការអនុវត្តការចូលរួមរបស់កុមារ។*

**សកម្មភាព៣.៣.១.១ :** កសាងសមត្ថភាព និងជំនាញពាក់ព័ន្ធនឹងការចូលរួមរបស់កុមារ ដើម្បីលើកកម្ពស់ការយល់ដឹងពីគោលការណ៍ណែនាំ ស្តីពីការអនុវត្តការចូលរួមរបស់កុមារដល់ស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងបណ្តាញកុមារ ដើម្បីធានាដល់ការអនុវត្តគោលការណ៍ រួមជាមួយលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ ដែលមានស្រាប់។

**សកម្មភាព ៣.៣.១.២:** លើកកម្ពស់ការចូលរួមរបស់កុមារនៅក្នុងវេទិកាពិភាក្សាគោលនយោបាយ គោលការណ៍ណែនាំ និងច្បាប់។

**សកម្មភាព៣.៣.១.៣ :** បង្កើត និងអនុវត្តតារាងបញ្ជីពិនិត្យតាមដានសម្រាប់ការអនុវត្តគោលការណ៍ការចូលរួមរបស់កុមារ។

**លទ្ធផល៣.៤ : ភាពជាដៃគូ៖** បានបង្កើនការសម្របសម្រួល និងសហប្រតិបត្តិការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្តីពីការអនុវត្តសិទ្ធិកុមារ។

*ទិន្នផល៣.៤.១ : ផែនការកិច្ចសហប្រតិបត្តិការ និងកិច្ចសហការ ត្រូវបានបង្កើត និងអនុវត្តដែលបញ្ជាក់ពីតួនាទីរបស់ ក.ជ.ក. និងស្ថាប័នសំខាន់ៗ ក្នុងការលើកកម្ពស់សិទ្ធិកុមារនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។*

**សកម្មភាព៣.៤.១.១ :** ផ្អែកតាមផែនទីនៃគណៈកម្មាធិការ និងក្រុមការងារដែលធ្វើការពាក់ព័ន្ធនឹងកុមារ បង្កើតយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការ និងកិច្ចសហការជាមួយគណៈកម្មាធិការ និងក្រុមការងារ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**សកម្មភាព៣.៤.១.២ :** បង្កើត និងអនុវត្តយុទ្ធសាស្ត្រកិច្ចសហការជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត និងក្រុមការងារខេត្តពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ ដើម្បីអនុវត្តការងារ និងសកម្មភាពស្តីពីសិទ្ធិកុមារនៅថ្នាក់ខេត្ត។

*ទិន្នផល៣.៤.២: ក.ជ.ក. ផ្តល់ព័ត៌មានជាទៀងទាត់ទៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសេចក្តីសង្កេតចុងក្រោយ ។*

**សកម្មភាព៣.៤.២.១:** កំណត់ចំនួនមន្ត្រីឲ្យសមរម្យ ផ្អែកតាមតួនាទី និងការទទួលខុសត្រូវការងារ ដើម្បីចូលរួមជាទៀងទាត់តាមក្រុមការងារតាមវិស័យ និងគណៈកម្មាធិការទាក់ទងនឹងកុមារ។

**សកម្មភាព៣.៤.២.២:** ផ្តល់ធាតុចូលស្តីពីសិទ្ធិកុមារ និងតាមដានជាមួយក្រសួងពាក់ព័ន្ធទៅលើរបាយការណ៍ការពិនិត្យតាមដានកុមារ និងបញ្ហាកុមារតាមរយៈកិច្ចប្រជុំក្រុមការងារបច្ចេកទេសចំរុះ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង អភិវឌ្ឍន៍ជនបទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងយុត្តិធម៌ ក្រសួងផែនការ ក្រសួងមហាផ្ទៃ និងក្រសួងទេសចរណ៍)

### ៤.២.៤ គោលដៅយុទ្ធសាស្ត្រទី៤ : បង្កើនសមត្ថភាពស្ថាប័ន និងភាពជាដៃគូ

**គោលបំណង** : ពង្រឹងសមត្ថភាពមន្ត្រី ក.ជ.ក. ថ្នាក់ជាតិ និងថ្នាក់ខេត្ត និងស្វែងរកធនធានដើម្បីអនុវត្តតួនាទី និងការទទួលខុសត្រូវក្នុងការសម្របសម្រួលជាមួយរាជរដ្ឋាភិបាល និងសង្គមស៊ីវិល

**លទ្ធផល ៤.១** : **រចនាសម្ព័ន្ធ៖** រចនាសម្ព័ន្ធរបស់ ក.ជ.ក. ត្រូវបានពង្រឹង។

***ទិន្នផល៤.១.១*** : *រចនាសម្ព័ន្ធ ក.ជ.ក. មាន៤អនុគណៈកម្មការដែលត្រូវរៀបចំកំណែទម្រង់។*

**សកម្មភាព៤.១.១.១** : បង្កើតអនុគណៈកម្មការពិគ្រោះយោបល់ និងកៀរគរធនធាន អនុគណៈកម្មការពិនិត្យតាមដាននិងវាយតម្លៃ និងរបាយការណ៍ អនុគណៈកម្មការច្បាប់ និងគោលនយោបាយ និងរក្សាអនុគណៈកម្មការពលកម្មកុមារ និងទម្រង់ផ្សេងៗទៀតនៃការកេងប្រវ័ញ្ចលើកុមារ។

**លទ្ធផល ៤.២** : **ផែនការសកម្មភាពប្រចាំឆ្នាំ និងការកៀរគរធនធាន៖** ធនធានរបស់ ក.ជ.ក. ត្រូវបានបង្កើនសម្រាប់សកម្មភាពអាទិភាពរបស់ ក.ជ.ក.។

***ទិន្នផល ៤.២.១*** : ***ក.ជ.ក. មានផែនការសកម្មភាពប្រចាំឆ្នាំ រួមជាមួយនឹងធនធាន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។***

**សកម្មភាព៤.២.១.១** : បង្កើតផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានសកម្មភាពអាទិភាពដោយភ្ជាប់ជាមួយនឹងប្រភពធនធាន និងបែងចែកថវិកាដល់ ក.ជ.ក. រាជធានី ខេត្ត សម្រាប់កិច្ចប្រជុំ និងការប្រមូលរបាយការណ៍។

**សកម្មភាព៤.២.១.២** : វាយតម្លៃ ក.ជ.ក. នៅថ្នាក់ក្រោមជាតិ ដោយមធ្យោបាយល្អបំផុតដើម្បីអនុវត្តអាណត្តិរបស់ខ្លួន ដោយមានផែនការសកម្មភាពច្បាស់លាស់។

**សកម្មភាព៤.២.១.៣** : ផ្តល់ការណែនាំផ្នែកបច្ចេកទេសបន្ថែមទៀតដល់ ក.ជ.ក. នៅថ្នាក់ក្រោមជាតិទៅលើតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។

**សកម្មភាព៤.២.១.៤** : រៀបចំរបាយការណ៍ប្រចាំឆ្នាំ ស្តីពីវឌ្ឍនភាពទៅលើសកម្មភាព និងលទ្ធផល។

***ទិន្នផល ៤.២.២*** : ***ក.ជ.ក. មានយុទ្ធសាស្ត្រកៀរគរធនធាន។***

**សកម្មភាព៤.២.២.១** : បង្កើត និងអនុវត្តយុទ្ធសាស្ត្រកៀរគរធនធានប្រចាំឆ្នាំដើម្បីសម្រេចបានភារកិច្ចជាក់លាក់ ដែលបានកំណត់នៅក្នុងផែនការសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក. និង ក.ជ.ក. រាជធានី ខេត្ត។

**សកម្មភាព៤.២.២.២** : បង្កើត និងផ្តល់ឱកាសសម្រាប់ដៃគូសាធារណៈ និងឯកជន ដើម្បីជំរុញការអនុវត្តសិទ្ធិកុមារក្នុងគោលដៅយុទ្ធសាស្ត្រ។

**លទ្ធផល ៤.៣** : **មន្ត្រី៖** មន្ត្រី ក.ជ.ក. មានសមត្ថភាពអនុវត្តតួនាទី និងការទទួលខុសត្រូវ។

***ទិន្នផល៤.៣.១*** : ***មន្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានពង្រឹងសមត្ថភាពស្តីពីសិទ្ធិកុមារ ដើម្បីមានការទទួលខុសត្រូវក្នុងការបំពេញតួនាទីរបស់ខ្លួន។***

**សកម្មភាព៤.៣.១.១** : កំណត់ពីលក្ខខណ្ឌការងារ និងរៀបចំផែនការកសាងសមត្ថភាពរបស់មន្ត្រីទាំងអស់ ផ្អែកតាមតម្រូវការនៃការទទួលខុសត្រូវរបស់មន្ត្រីនីមួយៗ។

**សកម្មភាព៤.៣.១.២** : រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល ដើម្បីបណ្តុះបណ្តាលដល់ថ្នាក់ក្រោមជាតិដោយប្រើប្រាស់សៀវភៅសិក្សាស្តីពីសិទ្ធិកុមារ។

**សកម្មភាព៤.៣.១.៣** : រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលសិទ្ធិកុមារកម្រិតខ្ពស់ដល់មន្ត្រីបច្ចេកទេស និងមន្ត្រីច្បាប់របស់ ក.ជ.ក. ស្តីពី(១)ការពិនិត្យតាមដាន និងការធ្វើរបាយការណ៍អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែមនានានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (២)ការធ្វើរបាយ ការណ៍តាមកាលកំណត់ នៃការវិភាគស្ថានភាពសិទ្ធិកុមារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និង(៣)ការរៀបចំច្បាប់ និងគោលនយោបាយ

**សកម្មភាព៤.៣.១.៤** : បង្កើនសមត្ថភាពមន្ត្រី ក្នុងការប្រើប្រាស់មូលដ្ឋានទិន្នន័យជាតិពាក់ព័ន្ធ រួមមាន មូលដ្ឋានទិន្នន័យឃុំ សង្កាត់ ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ ស្ថិតិសុខភាពជាតិ មូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មក្រីក្រ ស្ថិតិរបស់ក្រសួងផែនការ អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា។

**សកម្មភាព៤.៣.១.៥ :** បង្កើនសមត្ថភាពមន្ត្រីដើម្បីបង្កើត និងអនុវត្តយុទ្ធសាស្ត្រកៀរគរធនធាន និងការសរសេរសំណើនិងរបាយការណ៍កម្រិតមូលដ្ឋាន និងកម្រិតវិជ្ជាជីវៈ។

**សកម្មភាព៤.៣.១.៦ :** បង្កើនជំនាញភាសាអង់គ្លេសមន្ត្រី និងព័ត៌មានវិទ្យា។

**សកម្មភាព៤.៣.១.៧ :** វាយតម្លៃពីរបៀបរៀបចំបន្ទុកការងារឡើងវិញ ដូច្នេះសកម្មភាពត្រូវបានផ្តល់ជូនដល់មន្ត្រីកាន់តែច្រើន។

**សកម្មភាព ៤.៣.១.៨ :** អគ្គលេខាធិការដ្ឋាន ក.ជ.ក. ធ្វើទស្សនកិច្ចសិក្សាទៅប្រទេសពាក់ព័ន្ធ ដើម្បីសិក្សាពីគំរូនៃការពិនិត្យតាមដាន និងវាយតម្លៃដែលមានប្រសិទ្ធភាព។

***ទិន្នផល៤.៣.២ : មានផែនការដឹកនាំក្នុងការកំណត់ពីតម្រូវការជំនាញដឹកនាំ ដើម្បីលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ។***

**សកម្មភាព៤.៣.២.១ :** វាយតម្លៃពីជំនាញដឹកនាំចាំបាច់សម្រាប់ ក.ជ.ក. ដើម្បីអនុវត្តសកម្មភាពរបស់ខ្លួន។

**សកម្មភាព៤.៣.២.២ :** ស្វែងរកការគាំទ្រ និងជ្រើសរើសមន្ត្រី ដែលមានជំនាញតាមតម្រូវការ។

## ៤.៣ ការអនុវត្តយុទ្ធសាស្ត្រ

ការអនុវត្តផែនការយុទ្ធសាស្ត្រ៥ឆ្នាំ នេះ នឹងត្រូវបានណែនាំដោយយុទ្ធសាស្ត្រជាបន្តបន្ទាប់ ដើម្បីធានាថា ក.ជ.ក. នឹងសម្រេចបានគោលដៅរបស់ខ្លួន ដូចមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រនេះ។

វាមានសារៈសំខាន់បំផុតដែលអ្នកពាក់ព័ន្ធទាំងអស់ រួមទាំងសមាជិក ក.ជ.ក/ភ្នាក់ងារពាក់ព័ន្ធ អ្នកគ្រប់គ្រង និងមន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក. លេខាធិការដ្ឋាន ក.ជ.ក. រាជធានី ខេត្ត និងអ្នកពាក់ព័ន្ធ មានការយល់ដឹងពីផែនការយុទ្ធសាស្ត្រនេះ និងបានយល់ដឹងកាន់តែស៊ីជម្រៅពីតួនាទី និងការទទួលខុសត្រូវរៀងៗខ្លួន ពាក់ព័ន្ធនឹងការចូលរួមនៅក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្រនេះ។

ភាពជោគជ័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ គឺពឹងផ្អែកលើសមត្ថភាព និងលទ្ធភាពរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក. និងលេខាធិការដ្ឋាន ក.ជ.ក. រាជធានីខេត្ត ដើម្បីប្រតិបត្តិការផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ នេះ។ ដើម្បីសម្រេចគោលបំណងនេះ មានការងារជាច្រើនដែលត្រូវធ្វើពាក់ព័ន្ធនឹងការធ្វើឲ្យប្រសើរឡើងនូវចំណេះដឹងបច្ចេកទេសនិងសមត្ថភាពរបស់មន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក. និង ការគ្រប់គ្រង។ នេះជាលទ្ធភាពជួយអគ្គលេខាធិការដ្ឋាន ក.ជ.ក. ដើម្បីបង្កើនជំនឿទុកចិត្ត និងតួនាទីភាពជាអ្នកដឹកនាំរបស់ខ្លួន និងដើម្បីសម្រេចបានអាណត្តិរបស់ខ្លួន។ អគ្គលេខាធិការដ្ឋាន ក.ជ.ក. ត្រូវពង្រីកការងារឲ្យបានច្រើន ដើម្បីជួយលេខាធិការដ្ឋាន ក.ជ.ក. រាជធានី ខេត្ត ទៅតាមទិដ្ឋភាពផ្សេងៗគ្នា ប៉ុន្តែអ្វីដែលសំខាន់ជាងគេនោះ គឺ (១) ធានាថា លេខាធិការដ្ឋាន ក.ជ.ក. រាជធានី ខេត្ត មានការិយាល័យសមរម្យដោយមានសម្ភារបរិក្ខារចំបាច់ដើម្បីបម្រើការងារ (២) លើកកម្ពស់សមត្ថភាព និងចំណេះដឹងបច្ចេកទេស ដើម្បីសម្របសម្រួល ពិនិត្យតាមដាន និងធ្វើរបាយការណ៍ស្តីពីស្ថានភាពសិទ្ធិ

កុមារថ្នាក់រាជធានី ខេត្ត (៣) ស្វែងរកការឧបត្ថម្ភគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល និងដៃគូវិស័យឯកជន (៤) រៀបចំផែនការសកម្មភាពប្រចាំឆ្នាំនៅថ្នាក់ខេត្ត (៥) ជំនាញសរសេរគម្រោងនិងសរសេររបាយការណ៍ និង (៦) ជំនាញទំនាក់ទំនង។

ផែនការសកម្មភាពប្រចាំឆ្នាំលម្អិត ត្រូវបានបង្កើតដើម្បីប្រត្តិបត្តិផែនការយុទ្ធសាស្ត្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ត្រូវធ្វើការពិគ្រោះយោបល់ជាមួយមន្ត្រីពាក់ព័ន្ធ អ្នកគ្រប់គ្រងអគ្គលេខាធិការដ្ឋាន ក.ជ.ក លេខាធិការដ្ឋាន ក.ជ.ក រាជធានី ខេត្ត និងអ្នកពាក់ព័ន្ធ។ លេខាធិការដ្ឋាន ក.ជ.ក រាជធានី ខេត្ត ត្រូវរៀបចំផងដែរនូវផែនការសកម្មភាពប្រចាំឆ្នាំរបស់ខ្លួន ដែលចូលរួមបំពេញឲ្យផែនការយុទ្ធសាស្ត្រនេះ និងដែលស្របជាមួយ ឬក៏បំពេញបន្ថែមឲ្យផែនការសកម្មភាពប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក។ លេខាធិការដ្ឋាន ក.ជ.ក រាជធានី ខេត្ត ត្រូវទទួលបានការផ្គត់ផ្គង់ផ្នែកធនធានហិរញ្ញវត្ថុ និងធនធានមនុស្សចាំបាច់ ដើម្បីរៀបចំ និងអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ។

អគ្គលេខាធិការដ្ឋាន ក.ជ.ក ត្រូវការជាចាំបាច់នូវប្រភពធនធានហិរញ្ញវត្ថុ និងធនធានមនុស្សល្អៗ ដើម្បីសម្រេចបានគោលដៅយុទ្ធសាស្ត្រទាំងបួន ដែលបានបង្ហាញនៅក្នុងផែនការយុទ្ធសាស្ត្រនេះ។ បច្ចុប្បន្ន អគ្គលេខាធិការដ្ឋាន ក.ជ.ក ពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើមូលនិធិមកពីអង្គការ/ដៃគូអភិវឌ្ឍមួយចំនួនដើម្បីអនុវត្តផែនការសកម្មភាពរបស់ខ្លួន។ មូលនិធិទាំងនោះ គឺបានមកដោយមិនមានការព្រាងទុកនៅក្នុងគម្រោង និងផ្អែកតាមគម្រោង។ ភាគច្រើននៃគម្រោងដែលត្រូវបានអនុវត្ត ជាទូទៅត្រូវបានផ្តួចផ្តើមដោយភ្នាក់ងារមូលនិធិ។ ដូចច្នេះ ដើម្បីបង្ហាញពីភាពជាម្ចាស់ និងភាពខ្លាំងរបស់ស្ថាប័នរាជរដ្ឋាភិបាល ត្រូវចូលរួមផ្តល់ធនធានហរិញ្ញវត្ថុឲ្យបានគ្រប់គ្រាន់ដល់ ក.ជ.ក. ក្នុងការអនុវត្តសកម្មភាពរបស់ខ្លួន ។ មូលនិធិសម្រាប់ប្រត្តិបត្តិការចំណាយ ក៏ត្រូវមានការចូលរួមផងដែរពីអង្គការមិនមែនរដ្ឋាភិបាល/ដៃគូអភិវឌ្ឍ និងវិស័យឯកជន។ កិច្ចខិតខំប្រឹងប្រែងជាច្រើនទៀត គឺត្រូវធ្វើការវិនិយោគលើការកៀរគរធនធាន ជាពិសេសដោយមធ្យោបាយ នៃការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល/ដៃគូអភិវឌ្ឍ និងផ្នែកឯកជន។ ទាំងនេះនឹងធានាឲ្យមានការកើនឡើង និង/ឬក៏ប្រភពមូលនិធិកាន់តែមាននិរន្តរភាពសម្រាប់ការអនុវត្តគម្រោងដែលមិនបានព្រាងទុក និងគម្រោងដែលមានលក្ខណៈជាប្រព័ន្ធនៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រនោះកាន់តែច្រើន។

### ៤.៤ ការពិនិត្យតាមដាន និងការវាយតម្លៃ

ការវាស់វែងពីវឌ្ឍនភាពរបស់ផែនការយុទ្ធសាស្ត្ររបស់ ក.ជ.ក. ២០១៤-២០១៨ តម្រូវឲ្យមានក្របខ័ណ្ឌការងារពិនិត្យតាមដាន និងវាយតម្លៃច្បាស់លាស់។ ក្របខ័ណ្ឌការងារពិនិត្យតាមដាន និងវាយតម្លៃ នឹងផ្តល់ជាមូលដ្ឋានដើម្បីកំណត់ និងប្រមូលប្រភេទទិន្នន័យ/ព័ត៌មានដែលត្រូវការ ហើយវិភាគទិន្នន័យដែលប្រមូលបាន ដើម្បីវាយតម្លៃពីវឌ្ឍនភាពដែលឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រ។ ក្របខ័ណ្ឌការងារពិនិត្យតាមដាន និងវាយតម្លៃ ត្រូវមានសកម្មភាពដូចខាងក្រោមៈ

- ការពិនិត្យក្របខ័ណ្ឌការងារពិនិត្យតាមដាន និងវាយតម្លៃកន្លងមក ជាការចំបាច់ដើម្បីកំណត់ភាពខ្លាំង និងបញ្ហាប្រឈមនៃប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃជាមុន។ វាមានសារៈប្រយោជន៍ នៅពេលបង្កើតក្របខ័ណ្ឌការងារពិនិត្យតាមដាន និងវាយតម្លៃថ្មី។

- យន្តការនានាដើម្បីប្រមូល និងវិភាគទិន្នន័យ ដើម្បីវាយតម្លៃសមិទ្ធផលទាក់ទងនឹងគោលដៅយុទ្ធសាស្ត្រទាំង៤ នឹងត្រូវបង្កើតឡើងដើម្បីពិនិត្យតាមដានពីវឌ្ឍនភាពជាទៀងទាត់។ ការវិភាគនេះនឹងកើតមានជារៀងរាល់ឆ្នាំ។ បណ្តុំនៃសូចនាករវឌ្ឍនភាព នឹងត្រូវបង្កើតទម្រង់ប្រមូលទិន្នន័យ និងការងារពិនិត្យតាមដាន និងវាយតម្លៃ។ ប្រព័ន្ធមូលដ្ឋានទិន្នន័យតាមកុំព្យូទ័រ នឹងត្រូវបង្កើតដើម្បីរក្សាទុកទិន្នន័យ/ព័ត៌មានដែលប្រមូលបាន ក្នុងគោលបំណងពិនិត្យតាមដាន និងវាយតម្លៃ។ ទម្រង់ពិនិត្យតាមដាន និងបទដ្ឋានរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ នឹងត្រូវបង្កើត។ លេខាធិការដ្ឋាន ក.ជ.ក. រាជធានី ខេត្ត នឹងត្រូវឲ្យបំពេញទម្រង់ និងបទដ្ឋានរបាយការណ៍ ហើយផ្ញើជូនអគ្គលេខាធិការដ្ឋាន ក.ជ.ក. ជាទៀងទាត់។
- អគ្គលេខាធិការដ្ឋាន ក.ជ.ក. នឹងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំឆ្លើយតបទាំងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពប្រចាំឆ្នាំ ដោយប្រើប្រាស់មូលដ្ឋានទិន្ន័យ។ របាយការណ៍ប្រចាំឆ្នាំ នឹងផ្តល់ជាមូលដ្ឋានផងដែរសម្រាប់ណែនាំការកែលម្អចាំបាច់ដល់ផែនការយុទ្ធសាស្ត្រ និងប្រាប់ពីផែនការសកម្មភាពប្រចាំឆ្នាំថ្មី និងការងារពិនិត្យតាមដាន និងវាយតម្លៃ។
- មន្ត្រីពាក់ព័ន្ធនៅអគ្គលេខាធិការដ្ឋាន ក.ជ.ក. និងលេខាធិការដ្ឋាន ក.ជ.ក. ត្រូវបានបណ្តុះបណ្តាលជំនាញពិនិត្យតាមដាន និងវាយតម្លៃ និងបច្ចេកទេសប្រមូលទិន្នន័យ។
- ក.ជ.ក. នឹងបង្កើតគណៈកម្មការ ដើម្បីពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិពីវឌ្ឍនភាពឆ្លើយតបនឹងគោលដៅយុទ្ធសាស្ត្រ នៅឆ្នាំ២០១៦។ ការវាយតម្លៃនេះ ត្រូវធ្វើក្នុងឆ្នាំទី៣នៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ធ្វើដូច្នេះនឹងផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យលទ្ធផល ទិន្នផល និងសកម្មភាពសំខាន់នៃផែនការយុទ្ធសាស្ត្រ។
- ការវាយតម្លៃបញ្ចប់ផែនការយុទ្ធសាស្ត្រ នឹងត្រូវធ្វើនៅត្រីមាសចុងក្រោយនៃឆ្នាំទី៥ ដើម្បីពិនិត្យពីវឌ្ឍនភាព ក៏ដូចជា ដើម្បីជាព័ត៌មានអភិវឌ្ឍផែនការយុទ្ធសាស្ត្រថ្មី។

## ៨.៥ សូចនាករនៃការពិនិត្យតាមដាន និងវាយតម្លៃ

**គោលដៅយុទ្ធសាស្ត្រទី១ ៖ ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងរបាយការណ៍ស្តីពីសិទ្ធិកុមារ**

**គោលបំណង :** ធ្វើឲ្យប្រសើរឡើងនូវការអនុវត្តសិទ្ធិកុមារ តាមរយៈការពិនិត្យតាមដានស្ថានភាពសិទ្ធិកុមារដ៏មានប្រសិទ្ធភាពនៅក្នុងប្រទេសកម្ពុជា ដើម្បីផ្តល់របាយការណ៍ជូនរាជរដ្ឋាភិបាល គណៈកម្មាធិការសិទ្ធិកុមារ និងស្ថាប័នសិទ្ធិមនុស្សនៃ អ.ស.ប ទាន់ពេលវេលា និងប្រកបដោយគុណភាព។

**១.១ ក្របខណ្ឌការងារពិនិត្យតាមដាន និងការប្រមូលទិន្នន័យ**

**លទ្ធផល** : បានបង្កើតក្របខ័ណ្ឌការងារពិនិត្យតាមដាន និងការប្រមូលទិន្នន័យទូលំទូលាយ និងប្រព័ន្ធពិនិត្យតាមដាន ដែលបញ្ចូលទិន្នន័យពីគ្រប់វិស័យទាក់ទិនទៅនឹងការអនុវត្តសិទ្ធិកុមារ។

**សូនាករលទ្ធផល :** វិស័យសំខាន់ៗផ្តល់ទិន្នន័យទាន់ពេលវេលា ព្រមគ្នា និងសុខដុមនីយកម្មដល់ការប្រមូលទិន្នន័យ និងប្រព័ន្ធពិនិត្យតាមដានរបស់ ក.ជ.ក

**ប្រភពផ្ទៀងផ្ទាត់**:ការវាយតម្លៃពាក់កណ្តាល និងចុងបញ្ចប់អាណត្តិ

| ទិន្នផលរំពឹងទុក | សកម្មភាព | សូចនាករលទ្ធផល | ប្រភពផ្ទៀងផ្ទាត់ |
|---|---|---|---|
| **១.១.១** : ប្រព័ន្ធប្រមូលទិន្នន័យ និងការពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារត្រូវបានដាក់ឲ្យអនុវត្ត។ | **១.១.១.១ :** កំណត់តម្រូវការទិន្នន័យសំខាន់ៗ ដើម្បីតាមដានស្ថានភាពសិទ្ធិកុមារ ផ្អែកលើសូចនាករសិទ្ធិកុមាររបស់ ក.ជ.ក. និងការវិភាគអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប បន្ថែមទៀត ដើម្បីកំណត់ និងប្រមូលទិន្នន័យពីបណ្តាក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល វិទ្យាស្ថានស្រាវជ្រាវ សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ។ | មានប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងកំពុងដំណើរការ | របាយការណ៍ប្រចាំឆ្នាំរបស់ក.ជ.ក. |
| | **១.១.១.២ :** វាយតម្លៃភាពរីកចម្រើននៃប្រព័ន្ធគ្រប់គ្រងទិន្នន័យបច្ចុប្បន្ន ហើយផ្អែកលើការវិភាគនេះ ទិន្នន័យសំខាន់ៗត្រូវបានកំណត់សម្រាប់បង្កើត និងអនុវត្តប្រព័ន្ធប្រមូលទិន្នន័យថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ | សូចនាករសិទ្ធិកុមារត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ | ការប្រមូលទិន្នន័យ និងប្រព័ន្ធពិនិត្យតាមដាន |
| | **១.១.១.៣** : រៀបចំសៀវភៅណែនាំស្តីពីនីតិវិធី ដែលកំណត់ពីទិន្នន័យសម្រាប់ប្រមូលនិងវិភាគ ក៏ដូចជាពេលវេលាសម្រាប់ប្រមូលនិងវិភាគ។ | សៀវភៅណែនាំត្រូវបានប្រើប្រាស់ | សៀវភៅណែនាំប្រតិបត្តិការ |
| ១.១.២ : ប្រព័ន្ធប្រមូលទិន្នន័យពីវិស័យនានា ត្រូវបានធ្វើឲ្យប្រសើរឡើង នូវ | **១.១.២.១ :** សហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិ ប្រព័ន្ធព័ត៌មានកម្ពុជា (CamInfo) ប្រព័ន្ធមូលដ្ឋានទិន្នន័យឃុំ-សង្កាត់ និងប្រព័ន្ធទិន្នន័យផ្សេងៗទៀត ដើម្បីពិនិត្យឡើងវិញពីតម្រូវការយន្តការនៃការប្រមូលទិន្នន័យ និងកំណត់ភាព | ចំនួនក្រសួងដែលបានផ្តល់ទិន្នន័យតាមការស្នើសុំរបស់ ក.ជ.ក. | របាយការណ៍ប្រព័ន្ធពិនិត្យតាមដាន និង |

| | | | |
|---|---|---|---|
| គុណភាព សុខដុមនីយកម្ម និងស្របគ្នាជាមួយបទដ្ឋានជាតិ និងអន្តរជាតិ។ | ខ្វះខាតនៅក្នុងប្រភពដែលអាចរកបាន។<br>**១.១.២.២** : កំណត់ប្រភពទិន្នន័យដែលចាំបាច់ ដែលមិនអាចស្វែងរកបានក្នុងពេលបច្ចុប្បន្ន ដើម្បីពិនិត្យតាមដានអនុសញ្ញាស្តីពីសិទ្ធិកុមារ។<br>**១.១.២.៣** : បង្កើតយន្តការប្រមូលទិន្នន័យសម្រាប់ប្រភពទិន្នន័យទាំងអស់ និងបញ្ចូលសូចនាករបន្ថែមទៅក្នុងប្រព័ន្ធទិន្នន័យជាតិ។ | សូចនាករសិទ្ធិកុមារអាចបែងចែកតាមភេទ អាយុ ជាតិពន្ធុ និងពិការភាព តាមពេលសមរម្យ | ការប្រមូលទិន្នន័យ |
| **១.១.៣** : សមត្ថភាពរបស់សមាជិក ក.ជ.ក. ថ្នាក់ក្រោមជាតិ ទាក់ទិននឹងការពិនិត្យតាមដានស្ថានភាពសិទ្ធិកុមារត្រូវបានពង្រឹង។ | **១.១.៣.១** : កំណត់អាទិភាពសម្រាប់ធ្វើការពិនិត្យតាមដានបញ្ហាបន្ទាន់ និងការចូលរួមរបស់កុមារនៅក្នុងដំណើរការរបស់រាជរដ្ឋាភិបាល នៅថ្នាក់ក្រោមជាតិ។<br>**១.១.៣.២** : រៀបចំ និងអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងប្រមូលទិន្នន័យជាទៀងទាត់ ដែលរាយការណ៍ពីថ្នាក់ក្រោមជាតិ។ | គោលការណ៍ណែនាំសម្រាប់ប្រមូលទិន្នន័យពីថ្នាក់ក្រោមជាតិ<br><br>របាយការណ៍តាមកាលកំណត់នៃការប្រមូលទិន្នន័យ | របាយការណ៍ប្រព័ន្ធពិនិត្យតាមដាន និងការប្រមូលទិន្នន័យ |
| **១.២ : ការវិភាគទិន្នន័យ និងការរៀបចំរបាយការណ៍**<br>**លទ្ធផល** : ការវិភាគទិន្នន័យ និងការរៀបចំរបាយការណ៍កាន់តែមានប្រសិទ្ធភាព និងទាន់ពេលវេលា ត្រូវបានបញ្ចប់ ដោយផ្អែកតាមវិស័យសំខាន់ៗដែលពាក់ព័ន្ធទៅនឹងការអនុវត្តសិទ្ធិកុមារ។ | | **សូនាករលទ្ធផល** : ចំនួន និងប្រភេទរបាយការណ៍តាមកាលកំណត់ បានផ្តល់ជូនរាជរដ្ឋាភិបាល គណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប និងផ្តល់ព័ត៌មានដល់សង្គមស៊ីវិល<br>**ប្រភពផ្ទៀងផ្ទាត់** : ការវាយតម្លៃពាក់កណ្តាល និងចុងបញ្ចប់ | |
| **ទិន្នផលរំពឹងទុក** | **សកម្មភាព** | **សូចនាករលទ្ធផល** | **ប្រភពផ្ទៀងផ្ទាត់** |
| **១.២.១** : ក.ជ.ក. មានសមត្ថភាពវិភាគទិន្នន័យ និងរៀបចំរបាយការណ៍ជាប្រព័ន្ធស្តីពីស្ថានភាពសិទ្ធិកុមារនៅប្រទេសកម្ពុជា។ | **១.២.១.១** : បណ្តុះបណ្តាលមន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក. អំពីនីតិវិធីប្រមូលទិន្នន័យ ដោយប្រើប្រាស់សៀវភៅណែនាំសម្រាប់ការប្រមូលទិន្នន័យ និងប្រព័ន្ធពិនិត្យតាមដាន។<br>**១.២.១.២** : ស្វែងរកការគាំទ្របច្ចេកទេសដល់មន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក. ពីការវិភាគទិន្នន័យសម្រាប់ការវិភាគស្ថានភាពកុមារប្រចាំឆ្នាំ។ | ការបណ្តុះបណ្តាលដល់មន្ត្រីសំខាន់ៗបានបញ្ចប់ | របាយការណ៍បណ្តុះបណ្តាល<br><br>របាយការណ៍ប្រចាំឆ្នាំរបស់ ក.ជ.ក. |

| | | | |
|---|---|---|---|
| **១.២.២ :** របាយការណ៍វិភាគស្ថានភាពកុមារគ្រប់ជ្រុងជ្រោយត្រូវបានរៀបចំចងក្រងជារៀងរាល់ឆ្នាំ។ | **១.២.២.១ :** ពិនិត្យឡើងវិញ និងវិភាគទិន្នន័យដែលបានប្រមូល តាមរយៈការប្រមូលទិន្នន័យ និងការពិនិត្យតាមដានស្ថានភាពដោយផ្អែកលើអត្តបទគោលស្តីពីសិទ្ធិកុមារ។<br>**១.២.២.២ :** រៀបចំរបាយការណ៍វិភាគស្ថានភាពសិទ្ធិកុមារប្រចាំឆ្នាំ។<br>**១.២.២.៣ :** កំណត់ភាពខ្វះចន្លោះរបស់ទិន្នន័យដែលអាចរកបាន ដើម្បីបង្កើតរបៀបវារៈស្រាវជ្រាវបន្ថែម។ | របាយការណ៍វិភាគស្ថានភាពសិទ្ធិកុមារបានបញ្ចប់ជារៀងរាល់ឆ្នាំ និងចែកផ្សព្វផ្សាយ | របាយការណ៍វិភាគស្ថានភាពសិទ្ធិកុមារ<br><br>របាយការណ៍ប្រចាំឆ្នាំរបស់ ក.ជ.ក. |
| **១.២.៣ :** របាយការណ៍ស្តីពីការអនុវត្តសិទ្ធិកុមារ តាមកាលកំណត់នៅឆ្នាំ ២០១៨ ត្រូវបានផ្ញើជូនគណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប ទាន់ពេលវេលា និងប្រកបដោយគុណភាព។ | **១.២.៣.១ :** រៀបចំផែនការធ្វើសេចក្តីព្រាងសរសេររបាយការណ៍ ឆ្នាំ២០១៨ ដើម្បីកំណត់នូវទិន្នន័យខ្វះចន្លោះ និងស្វែងរកព័ត៌មាន ដើម្បីធ្វើឲ្យរបាយការណ៍នេះមានលក្ខណៈពេញលេញ។<br>**១.២.៣.២ :** រៀបចំរបាយការណ៍ស្តីពីការអនុវត្តសិទ្ធិកុមារ ជូនគណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប នៅឆ្នាំ២០១៨ និង តាមដាននិងទទួលរាល់អនុសាសន៍។ | របាយការណ៍អនុសញ្ញាសិទ្ធិកុមារបានបញ្ចប់ទាន់ពេលវេលា និងប្រកបដោយគុណភាព | របាយការណ៍តាមកាលកំណត់ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមាររបស់ ក.ជ.ក. និងតាមដាន |
| **១.៣: ការស្រាវជ្រាវ**<br>**លទ្ធផល :** ធ្វើឲ្យប្រសើរឡើងការយល់ដឹងពីស្ថានភាពសិទ្ធិកុមារដោយផ្អែកលើភស្តុតាង និងការអនុវត្តប្រកបដោយជោគជ័យ។ | | **សូនាករលទ្ធផល :** ការវាយតម្លៃសិទ្ធិកុមារសំខាន់ៗ គឺផ្អែកលើការស្រាវជ្រាវល្អៗបែបវិទ្យាសាស្ត្រ<br>**ប្រភពផ្ទៀងផ្ទាត់ :** ការវាយតម្លៃពាក់កណ្តាល និងចុងបញ្ចប់ | |
| **ទិន្នផលរំពឹងទុក** | **សកម្មភាព** | **សូចនាករលទ្ធផល** | **ប្រភពផ្ទៀងផ្ទាត់** |
| **១.៣.១ :** ការស្រាវជ្រាវត្រូវបានបញ្ចប់ ហើយធ្វើការចែករំលែក ដើម្បីឲ្យការយល់ដឹងពីស្ថានភាពសិទ្ធិកុមារក្នុងប្រទេសកម្ពុជាកាន់តែល្អប្រសើរ។ | **១.៣.១.១ :** រៀបចំរបៀបវារៈនៃការស្រាវជ្រាវ ដោយផ្អែកលើភាពខ្វះចន្លោះនៃទិន្នន័យដើម្បីផ្តល់នូវការយល់ដឹងពីស្ថានភាពសិទ្ធិកុមារ។<br>**១.៣.១.២ :** កំណត់ប្រភពធនធានសម្រាប់ការគាំទ្រ ឬភាពជាដៃគូ ដើម្បីបញ្ចប់ការស្រាវជ្រាវទៅលើភាពខ្វះចន្លោះក្នុងវិស័យនានា ដើម្បីឆ្លើយតបទៅនឹងសិទ្ធិកុមារ។ | ចំនួនតម្រូវការសិក្សាស្រាវជ្រាវ<br>ចំនួនការសិក្សាស្រាវជ្រាវបានបញ្ចប់ ឬបានចូលរួមជារៀងរាល់ឆ្នាំ | របាយការណ៍ប្រចាំឆ្នាំ<br><br>របាយការណ៍សិក្សាស្រាវជ្រាវ |

| | | | |
|---|---|---|---|
| | **១.៣.១.៣** : បំពេញ ឬសហការគ្នាលើការស្រាវជ្រាវពីភាពខ្វះចន្លោះតាមវិស័យ ដែលមានសារៈសំខាន់សម្រាប់កុមារ។ | | |
| **គោលដៅយុទ្ធសាស្ត្រទី២ ៖ ពង្រឹងយន្តការការពារកុមារ**<br>គោលបំណង : បង្កើតផែនការសកម្មភាព ច្បាប់ និងគោលនយោបាយដើម្បីការពារសិទ្ធិកុមារកាន់តែល្អប្រសើរ។ | | | |
| **២.១: ពិនិត្យឡើងវិញគោលនយោបាយ**<br>**លទ្ធផល** : ការធ្វើឲ្យប្រសើរនូវក្របខណ្ឌ គោលនយោបាយ ដើម្បីលើកកម្ពស់ការអនុវត្តសិទ្ធិកុមារជាមួយនឹងការបង្កើនថវិកា។ | | **សូនាករលទ្ធផល** : ក្រសួងសំខាន់ៗមានបញ្ចូលសិទ្ធិកុមារនៅក្នុងផែនការយុទ្ធ សាស្ត្ររបស់ពួកគេ ស្របតាមផែនការជាតិអភិវឌ្ឍន៍កុមារ។ ភាគរយនៃថវិកាសម្រាប់កុមារកើនឡើង<br>**ប្រភពផ្ទៀងផ្ទាត់** : ការវាយតម្លៃពាក់កណ្តាល និងចុងបញ្ចប់នៃផែនការសកម្មភាពជាតិសម្រាប់កុមារ ផែនការតាមវិស័យ ផែនការសកម្មភាពជាតិសម្រាប់កុមារ | |
| **ទិន្នផលរំពឹងទុក** | **សកម្មភាព** | **សូចនាករលទ្ធផល** | **ប្រភពផ្ទៀងផ្ទាត់** |
| **២.១.១** : ផែនការជាតិសម្រាប់កុមារត្រូវបានបញ្ចប់ និងបង្កើតផែនការយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់សិទ្ធិកុមារ រួមបញ្ចូលកុមារ នៅក្នុងស្ថានភាពងាយរងគ្រោះជាពិសេស និងការលើកកម្ពស់ការលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាប្រឆាំងកុមារ។ | **២.១.១.១** : ពិនិត្យផែនការតាមវិស័យ តាមក្រសួងពាក់ព័ន្ធដែលទាក់ទងនឹងសិទ្ធិកុមារ និងកំណត់ភាពខ្វះចន្លោះ និងធ្វើឲ្យសុខដុមនីយកម្ម សកម្មភាពដើម្បីពង្រឹងការឆ្លើយតបទៅនឹងស្ថាប័នចំពោះការអនុវត្តសិទ្ធិកុមារ។<br>**២.១.១.២** : រៀបចំសម្របសម្រួលផែនការជាតិដើម្បីកុមារ ជាមួយកម្មវិធីរបស់អ្នកពាក់ព័ន្ធសំខាន់ៗរួមមាន អាជ្ញាធរពាក់ព័ន្ធ និងសង្គមស៊ីវិល រួមទាំងកុមារ។<br>**២.១.១.៣** : បង្កើតប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តផែនការជាតិសម្រាប់កុមារ ទាំងការវាយតម្លៃពាក់កណ្តាល និងការវាយតម្លៃបញ្ចប់អាណត្តិ។ | មានផែនការជាតិអភិវឌ្ឍន៍កុមារ<br>ការវាយតម្លៃពាក់កណ្តាល និងចុងបញ្ចប់នៃផែនការជាតិអភិវឌ្ឍន៍កុមារ | របាយការណ៍ប្រចាំឆ្នាំរបស់ ក.ជ.ក.<br>របាយការណ៍វាយតម្លៃពាក់កណ្តាល និងចុងបញ្ចប់នៃផែនការជាតិអភិវឌ្ឍន៍កុមារ |
| ២.១.២ : យុទ្ធសាស្ត្រទាក់ទាញមតិគាំទ្រថវិកាសង្គម ត្រូវបានបង្កើត និងអនុវត្ត។ | **២.១.២.១** : ផ្សព្វផ្សាយរបកគំហើញនៃការស្រាវជ្រាវថវិកាសង្គម។ | ចំនួនថវិកាតាមវិស័យបានបញ្ចូលក្នុងយុទ្ធសាស្ត្រទាក់ទាញមតិគាំទ្រ<br>ភាគរយនៃថវិកាកើនឡើងក្នុងវិស័យ | របាយការណ៍ក្រុមការងារថវិកាកុមារ<br>ការផ្សព្វផ្សាយរបាយ |

| | | | |
|---|---|---|---|
| | **២.១.២.២** : បង្កើតក្រុមការងារថវិកាសម្រាប់កុមារ ដើម្បីបង្កើត និងអនុវត្តយុទ្ធសាស្ត្រទាក់ទាញមតិគាំទ្រថវិកាសង្គម ដោយផ្តោតលើសិទ្ធិកុមារ។<br>**២.១.២.៣** : ក.ជ.ក. សហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ស្តីពីសុខុមាលភាពកុមារ។ | សំខាន់ៗ | ការណ៍ស្រាវជ្រាវថវិកាសង្គម<br>ថវិកាជាតិ |
| **២.២៖ របៀបវារៈច្បាប់ស្តីពីការការពារកុមារ និងនីតិវិធីបណ្តឹង**<br>**លទ្ធផល៖** ក្របខណ្ឌច្បាប់ស្តីពីសិទ្ធិកុមារ និងការការពារកុមាររបស់ប្រទេសកម្ពុជាត្រូវបានពង្រឹង | | **សូនាករលទ្ធផល :** បានបង្កើនប្រសិទ្ធភាពក្របខណ្ឌច្បាប់ការការពារកុមារ<br>**ប្រភពផ្ទៀងផ្ទាត់ :** ការវាយតម្លៃពាក់កណ្តាល និងចុងបញ្ចប់ | |
| **ទិន្នផលរំពឹងទុក** | **សកម្មភាព** | **សូចនាករលទ្ធផល** | **ប្រភពផ្ទៀងផ្ទាត់** |
| **២.២.១** : យុទ្ធសាស្ត្រទាក់ទាញមតិគាំទ្ររបៀបវារៈច្បាប់ដោយភ្ជាប់ជាមួយនឹងអនុសាសន៍ ដើម្បីវិសោធនកម្មសម្រាប់សកម្មភាពគោលនយោបាយ និងច្បាប់ថ្មី ត្រូវបានបង្កើត និងបង្ហាញជូនដល់ស្ថាប័នសមស្រប។ | **២.២.១.១** : បង្កើតយុទ្ធសាស្ត្រអាទិភាពសម្រាប់សកម្មភាពគោលនយោបាយ និងច្បាប់ដើម្បីបញ្ចូលសិទ្ធិកុមារដោយផ្អែកតាមការវិភាគភាពខ្វះចន្លោះនៃច្បាប់ការការពារកុមារ និងការស្វែងយល់បន្ថែមពីស្ថានភាពបច្ចុប្បន្ន។<br>**២.២.១.២** : ពិនិត្យឡើងវិញយុទ្ធសាស្ត្រអាទិភាពសម្រាប់សកម្មភាព គោលនយោបាយ និងច្បាប់ ដើម្បីធានាថាពួកគេធានាសិទ្ធិរបស់ប្រជាជនងាយរងគ្រោះជាពិសេស រួមបញ្ចូលកុមារក្នុងការថែទាំជំនួសកុមារនៅមណ្ឌលឃុំខ្លួន កុមារពិការ កុមារបម្លាស់ទី កុមារជនជាតិភាគតិច និងសាសនាភាគតិច ជាពិសេសកុមារងាយរងគ្រោះ។<br>**២.២.១.៣** : ស្វែងរកឱកាសកិច្ចសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីទាក់ទាញមតិគាំទ្រសម្រាប់ការអនុវត្តគោលនយោបាយ និងច្បាប់ឲ្យបានត្រឹមត្រូវ រួមទាំងពង្រីកបទដ្ឋានអង្គការសុវត្ថិភាពកុមារ ទៅជាបទដ្ឋានសុវត្ថិភាពកុមារគ្រប់វិស័យ/គ្រប់ផ្នែក។<br>**២.២.១.៤** : ទាក់ទាញមតិគាំទ្រដើម្បីរៀបចំប្រកាស និងអនុក្រឹត្យថ្មី ដើម្បីការការពារកុមារដោយផ្អែកលើយុទ្ធសាស្ត្រអាទិភាពសម្រាប់សកម្មភាព គោលនយោបាយ និងច្បាប់ថ្មី។ សហការជាមួយក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពី | មានចំនួនអនុក្រឹត្យ ឬប្រកាស<br>បង្កើនថវិកាសម្រាប់កុមារក្នុងវិស័យផ្សេងៗ | ច្បាប់ និងគោលនយោបាយត្រូវបានរៀបចំ<br>របាយការណ៍វាយតម្លៃពាក់កណ្តាល និងចុងបញ្ចប់<br>របាយការណ៍ប្រចាំឆ្នាំ |

| | | | |
|---|---|---|---|
| | កុមារកំព្រានិងកុមារងាយរងគ្រោះ ក្រសួងសង្គមកិច្ច អតីតយុទ្ធ និងយុវនីតិសម្បទា និងដៃគូសំខាន់ៗដទៃទៀតក្នុងកិច្ចខិតខំប្រឹងប្រែងនេះ។ | | |
| **២.២.២** : ប្រព័ន្ធការការពារកុមារថ្នាក់ជាតិ និងយន្តការនីតិវិធីបណ្ដឹងរបស់រាជរដ្ឋាភិបាល មានភាពច្បាស់លាស់ និងមានភាពល្អប្រសើរ។ | **២.២.២.១** : រៀបចំវេទិកាពិភាក្សាជាមួយក្រសួងពាក់ព័ន្ធ ដើម្បីបង្កើតស្ថាប័នសម្របសម្រួលសម្រាប់ការពារកុមារនៅក្នុងប្រទេសកម្ពុជា។<br>**២.២.២.២** : ស្វែងរកការគាំទ្រជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីយន្តការប្រព័ន្ធការពារកុមារដោយបញ្ជាក់ពីតួនាទីរបស់ក្រសួងពាក់ព័ន្ធ ក្នុងការការពារ បង្ការ និងផ្ដល់សេវានិងស្ដារនីតិសម្បទាកុមារ ដោយផ្អែកតាមបទដ្ឋានដែលបានអនុវត្តល្អៗកន្លងមក។<br>**២.២.២.៣:** សិក្សា និងផ្ដល់សច្ចាប័នលើពិធីសារបន្ថែមស្ដីពីនីតិវិធីបណ្ដឹង។<br>**២.២.២.៤:** សិក្សាពីនីតិវិធី នៃការបង្កើតយន្តការទទួលពាក្យបណ្ដឹងពាក់ព័ន្ធនឹងបញ្ហាកុមារ។ | ចំនួនវេទិកាពិភាក្សាដែលបានរៀបចំ<br>មានប្រព័ន្ធការការពារកុមារ<br>ពិធីសារបន្ថែមស្ដីពីនីតិវិធីបណ្ដឹងបានផ្ដល់សច្ចាប័ន<br>មានយន្តការទទួលពាក្យបណ្ដឹងពាក់ព័ន្ធនឹងបញ្ហាកុមារ | របាយការណ៍កិច្ចប្រជុំ |
| **គោលដៅយុទ្ធសាស្ត្រទី៣ ៖ លើកកម្ពស់ការយល់ដឹង និងទាក់ទាញមតិគាំទ្រ**<br>**គោលបំណង** : បង្កើនចំណេះដឹងសិទ្ធិកុមារដល់ក្រសួង ស្ថាប័ន សង្គមស៊ីវិល សហគមន៍ មាតាបិតា និងកុមារ ដើម្បីធ្វើការរួមគ្នាឲ្យប្រសើរឡើងដើម្បីបំពេញនូវសិទ្ធិ និងការទទួលខុសត្រូវចំពោះកុមារ។ | | | |
| **៣.១ : ការបណ្ដុះបណ្ដាលសិទ្ធិកុមារ**<br>**លទ្ធផល** : បានបង្កើនសមត្ថភាពអាជ្ញាធរពាក់ព័ន្ធ ដើម្បីអនុវត្តសិទ្ធិកុមារ។ | | **សូនាករលទ្ធផល :** បានបង្កើនចំណេះដឹង និងផ្លាស់ប្ដូរឥរិយាបទរបស់អ្នកចូលរួមក្នុងកម្មវិធី<br>**ប្រភពផ្ទៀងផ្ទាត់ :** របាយការណ៍ព្រឹត្តិការណ៍ | |
| **ទិន្នផលរំពឹងទុក** | **សកម្មភាព** | **សូចនាករលទ្ធផល** | **ប្រភពផ្ទៀងផ្ទាត់** |
| **៣.១.១** : សេចក្ដីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារ និងពិធីសារបន្ថែមត្រូវបានផ្សព្វផ្សាយ | **៣.១.១.១** : ផ្សព្វផ្សាយសេចក្ដីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារដល់អាជ្ញាធរពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។<br>**៣.១.១.២** : ផលិត និងផ្សព្វផ្សាយសេចក្ដីសង្កេតចុងក្រោយរបស់គណៈកម្មាធិការ | ចំនួនកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយស្ដីពីសេចក្ដីសង្កេតចុងក្រោយ និងពិធីសារបន្ថែមដល់ក្រុមផ្សេងៗគ្នា | របាយការណ៍ប្រចាំឆ្នាំរបស់ ក.ជ.ក. |

| | | | |
|---|---|---|---|
| ទូលំទូលាយ។ | សិទ្ធិកុមារក្នុងទម្រង់កុមារមេត្រី និងឪពុកម្ដាយមេត្រី។<br>**៣.១.១.៣** : ផ្សព្វផ្សាយពិធីសារបន្ថែមដល់អាជ្ញាធរពាក់ព័ន្ធ នៅថ្នាក់ជាតិ និងក្រោមជាតិ។ | | |
| **៣.១.២** : ក្រុមដែលមានវិជ្ជាជីវៈ ដូចជា ចៅក្រម មេធាវី អ្នកអនុវត្តច្បាប់ មន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ គ្រូបង្រៀន បុគ្គលិកសុខាភិបាល អ្នកចិត្តសាស្ត្រ និងអ្នកធ្វើការសង្គមត្រូវបានពង្រឹងសមត្ថភាពផ្នែកសិទ្ធិកុមារ។ | **៣.១.២.១** : បង្កើតបទដ្ឋានជាតិសម្រាប់បណ្ដុះបណ្ដាលអំពីសិទ្ធិកុមារ និងច្បាប់។<br>**៣.១.២.២** : កសាងភាពជាដៃគូជាមួយក្រសួងពាក់ព័ន្ធ ដើម្បីផ្ដល់ការបណ្ដុះបណ្ដាលដល់អ្នកមានវិជ្ជាជីវៈឲ្យចំគោលដៅ ដើម្បីការពារសិទ្ធិកុមារ រួមទាំងកុមារនៅក្នុងស្ថានភាពងាយរងគ្រោះជាពិសេស និងលើកកម្ពស់ការចូលរួមរបស់កុមារ។<br>**៣.១.២.៣** : លើកកម្ពស់ និងសម្របសម្រួលក្រសួងនីមួយៗ ធ្វើការផ្សព្វផ្សាយសិទ្ធិកុមារដល់ភ្នាក់ងារសង្គមស៊ីវិល ដែលធ្វើការងារពាក់ព័ន្ធនឹងវិស័យរបស់ស្ថាប័នពួកគេ។ | បទដ្ឋានជាតិសម្រាប់កម្មវិធីបណ្ដុះបណ្ដាល<br>ចំនួនក្រុមដែលមានវិជ្ជាជីវៈ ដែលបានទទួលការបណ្ដុះបណ្ដាលស្ដីពីសិទ្ធិកុមារ<br>ចំនួនវគ្គបណ្ដុះបណ្ដាលដល់កុមារដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះជាពិសេស | របាយការណ៍បណ្ដុះបណ្ដាល |
| **៣.២ : បង្កើនការយល់ដឹងសិទ្ធិកុមារជាសាធារណៈ**<br>**លទ្ធផល** : សង្គមស៊ីវិល គ្រួសារ និងកុមារ មានការកើនឡើងនូវចំណេះដឹងពីសិទ្ធិកុមារ។ | | **សូនាករលទ្ធផល** : ភាគរយនៃក្រុមគោលដៅបង្ហាញថាចំណេះដឹងមានការកើនឡើង<br>**ប្រភពផ្ទៀងផ្ទាត់** : របាយការណ៍ព្រឹត្តិការណ៍ | |
| **ទិន្នផលរំពឹងទុក** | **សកម្មភាព** | **សូចនាករលទ្ធផល** | **ប្រភពផ្ទៀងផ្ទាត់** |
| **៣.២.១** : យុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយព្រឹត្តិការណ៍លើកកម្ពស់ចំណេះដឹង និងសម្ភារសម្រាប់ផ្សព្វផ្សាយត្រូវបានផលិត ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈផ្នែកសិទ្ធិកុមារ និអនុសញ្ញាស្ដីពីសិទ្ធិកុមារ | **៣.២.១.១** : លើកកម្ពស់យុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយជាតិ ដើម្បីផ្សព្វផ្សាយឲ្យទូលំទូលាយដល់កុមារ និងគ្រួសារឲ្យយល់ដឹងពីអនុសញ្ញាស្ដីពីសិទ្ធិកុមារ។<br>**៣.២.១.២** : ជំរុញឲ្យមានព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹង នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចជា ទិវាកុមារអន្តរជាតិ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ និងផ្សេងៗទៀត។<br>**៣.២.១.៣**: ផលិត និងចែកចាយសម្ភារសម្រាប់ផ្សព្វផ្សាយ ដូចជា ព្រឹត្តិបត្រព័ត៌មាន ខិតប័ណ្ណ ប័ណ្ណផ្សព្វផ្សាយស្ដីពីសិទ្ធិកុមារ និងអនុសញ្ញាសិទ្ធិកុមារ។ | ចំនួនយុទ្ធនាការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានជាតិស្ដីពីសិទ្ធិកុមារ<br>ចំនួនព្រឹត្តិការណ៍លើកកម្ពស់ចំណេះដឹង<br>ចំនួនសម្ភារសម្រាប់ផ្សព្វផ្សាយស្ដីពីសិទ្ធិកុមារបានបោះពុម្ព និងចែកផ្សព្វផ្សាយ | របាយការប្រចាំឆ្នាំរបស់ ក.ជ.ក.<br>របាយការណ៍អង្គការមិនមែនរដ្ឋាភិបាល |

| | | | |
|---|---|---|---|
| | **៣.២.១.៤** : បន្តលើកកម្ពស់គេហទំព័ររបស់ ក.ជ.ក.។<br>**៣.២.១.៥** : ផ្តល់ឱកាសពិភាក្សា និងវិភាគលើបញ្ហាសិទ្ធិកុមារ តាមរយៈវេទិកាសាធារណៈ ដែលមានការចូលរួមពីអង្គការយុវជន សមាគមពាណិជ្ជកម្ម ស្ថាប័នស្រាវជ្រាវ និងពាណិជ្ជកម្ម ដើម្បីលើកកម្ពស់ការយល់ដឹង និងទាក់ទាញការគាំទ្រគោលនយោបាយស្តីពីយន្តការ ការការពារ។ | ចំនួនវេទិកាដែលមានកុមារចូលរួម (បែងចែកតាមភេទ)<br>ចំនួនអ្នកចូលទស្សនាគេហទំព័រ | |
| **៣.៣ : ការចូលរួមរបស់កុមារ**<br>**លទ្ធផល** : បង្កើនការចូលរួមរបស់កុមារក្នុងការធ្វើផែនការ ការអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃគោលនយោបាយ និងកម្មវិធីទាក់ទងនឹងសិទ្ធិកុមារ។ | | **សូនាករលទ្ធផល** : ចំនួនកុមារដែលចូលរួមក្នុងសកម្មភាពផ្សេងៗ<br>**ប្រភពផ្ទៀងផ្ទាត់** : របាយការណ៍ប្រចាំឆ្នាំរបស់ថ្នាក់ជាតិ និងក្រោមជាតិ | |
| **ទិន្នផលរំពឹងទុក** | **សកម្មភាព** | **សូចនាករលទ្ធផល** | **ប្រភពផ្ទៀងផ្ទាត់** |
| **៣.៣.១** : ក.ជ.ក. ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអាជ្ញាធរពាក់ព័ន្ធ ត្រូវបានពង្រឹងសមត្ថភាពស្តីពីគោលការណ៍ណែនាំស្តីពីការអនុវត្តការចូលរួមរបស់កុមារ។ | **៣.៣.១.១** : កសាងសមត្ថភាព និងជំនាញពាក់ព័ន្ធនឹងការចូលរួមរបស់កុមារដើម្បីលើកកម្ពស់ការយល់ដឹងពីគោលការណ៍ណែនាំ ស្តីពីការអនុវត្តការចូលរួមរបស់កុមារដល់ស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងបណ្តាញកុមារដើម្បីធានាដល់ការអនុវត្តគោលការណ៍ រួមជាមួយលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ ដែលមានស្រាប់។<br>**៣.៣.១.២**: លើកកម្ពស់ការចូលរួមរបស់កុមារនៅក្នុងវេទិកាពិភាក្សាគោលនយោបាយ គោលការណ៍ណែនាំ និងច្បាប់។<br>**៣.៣.១.៣** : បង្កើត និងអនុវត្តតារាងបញ្ជីពិនិត្យតាមដានសម្រាប់ការអនុវត្តគោលការណ៍ការចូលរួមរបស់កុមារ។ | ចំនួនអង្គការមិនមែនរដ្ឋាភិបាល និងក្រុមរាជរដ្ឋាភិបាល បានបណ្តុះបណ្តាលគោលការណ៍ណែនាំស្តីពីការចូលរួមរបស់កុមារ<br>ចំនួនវគ្គ ឬកិច្ចប្រជុំធ្វើផែនការរបស់រាជរដ្ឋាភិបាលដោយមានកុមារចូលរួម<br>ចំនួនបណ្តាញកុមារដែលត្រូវបានបង្កើត | របាយការណ៍អង្គការមិនមែនរដ្ឋាភិបាល<br>របាយការប្រចាំឆ្នាំរបស់ ក.ជ.ក. |
| **៣.៤ : ភាពជាដៃគូ**<br>**លទ្ធផល** : បានបង្កើនការសម្របសម្រួល និងសហប្រតិបត្តិការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្តីពីការអនុវត្តសិទ្ធិកុមារ។ | | **សូនាករលទ្ធផល** : បង្កើនចំនួនសេចក្តីសង្កេតចុងក្រោយដែលបានដោះស្រាយ<br>**ប្រភពផ្ទៀងផ្ទាត់** : របាយការណ៍ ក.ជ.ក. | |
| **ទិន្នផលរំពឹងទុក** | **សកម្មភាព** | **សូចនាករលទ្ធផល** | **ប្រភពផ្ទៀងផ្ទាត់** |

| | | | |
|---|---|---|---|
| **៣.៤.១ :** ផែនការកិច្ចសហប្រតិបត្តិការ និងកិច្ចសហការត្រូវបានបង្កើត និងអនុវត្តដែលបញ្ជាក់ពីតួនាទីរបស់ ក.ជ.ក. និងស្ថាប័នសំខាន់ៗក្នុងការលើកកម្ពស់សិទ្ធិកុមារនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។ | **៣.៤.១.១**: ផ្អែកតាមផែនទីនៃគណៈកម្មាធិការ និងក្រុមការងារដែលធ្វើការពាក់ព័ន្ធនឹងកុមារ បង្កើតយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការ និងកិច្ចសហការជាមួយគណៈកម្មាធិការ និងក្រុមការងារ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។<br>**៣.៤.១.២**:បង្កើត និងអនុវត្តយុទ្ធសាស្ត្រកិច្ចសហការជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត និងក្រុមការងារខេត្តពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ ដើម្បីអនុវត្តការងារ និងសកម្មភាពស្តីពីសិទ្ធិកុមារនៅថ្នាក់ខេត្ត។ | ចំនួនគណៈកម្មាធិការ ឬក្រុមផ្សេងៗទៀត ដែលមន្ត្រី ក.ជ.ក. ចូលរួម<br>ចំនួនផែនការតាមវិស័យ ឬរបាយការណ៍ផ្សេងៗទៀតដែលបានព័ត៌មានពី ក.ជ.ក<br>មានផែនការកិច្ចសហប្រតិបត្តិការ និងចំនួនសកម្មភាពដែលធ្វើជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត<br>ចំនួនកិច្ចប្រជុំសម្របសម្រួលដែលបានរៀបចំដោយ ក.ជ.ក.<br>ការកើនឡើងចំនួនសកម្មភាពដែលចូលរួម | របាយការប្រចាំឆ្នាំរបស់ ក.ជ.ក.<br>ផែនការតាមវិស័យ |
| **៣.៤.២ :** ក.ជ.ក. ផ្តល់ព័ត៌មានជាទៀងទាត់ទៅក្នុងយុទ្ធសាស្ត្រនិងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីសេចក្តីសង្កេតចុងក្រោយ ។ | **៣.៤.២.១ :** កំណត់ចំនួនមន្ត្រីឲ្យសមរម្យ ផ្អែកតាមតួនាទី និងការទទួលខុសត្រូវការងារ ដើម្បីចូលរួមជាទៀងទាត់តាមក្រុមការងារតាមវិស័យ និងគណៈកម្មាធិការទាក់ទងនឹងកុមារ។<br>**៣.៤.២.២:** ផ្តល់ធាតុចូលស្តីពីសិទ្ធិកុមារ និងតាមដានជាមួយក្រសួងពាក់ព័ន្ធទៅលើរបាយការណ៍ការពិនិត្យតាមដានកុមារ និងបញ្ហាកុមារតាមរយៈកិច្ចប្រជុំក្រុមការងារបច្ចេកទេសចំរុះ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងយុត្តិធម៌ ក្រសួងផែនការ ក្រសួងមហាផ្ទៃ និងក្រសួងទេសចរណ៍) | ចំនួនមន្ត្រី និងឬក្រុមការងារដោយតំណាងពី ក.ជ.ក.<br>ចំនួនផែនការតាមវិស័យ ឬការរៀបចំផែនការសកម្មភាពដោយមានព័ត៌មានស្តីពីសិទ្ធិកុមារ ពី ក.ជ.ក. | របាយការណ៍មន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក និងរបាយការណ៍ប្រចាំឆ្នាំ |
| **គោលដៅយុទ្ធសាស្ត្រទី៤ ៖ បង្កើនសមត្ថភាពស្ថាប័ន និងភាពជាដៃគូ**<br>**គោលបំណង :** ពង្រឹងសមត្ថភាពមន្ត្រី ក.ជ.ក. ថ្នាក់ជាតិ និងថ្នាក់ខេត្ត និងស្វែងរកធនធានដើម្បីអនុវត្តតួនាទី និងការទទួលខុសត្រូវក្នុងការ សម្របសម្រួលជាមួយរាជរដ្ឋាភិបាល និងសង្គមស៊ីវិល។ | | | |

| **៤.១ : រចនាសម្ព័ន្ធ**<br>**លទ្ធផល** : រចនាសម្ព័ន្ធរបស់ ក.ជ.ក. ត្រូវបានពង្រឹង។ | | **សូនាករលទ្ធផល** : ក.ជ.ក. បង្កើនសមត្ថភាព ដើម្បីអនុវត្តសកម្មភាព<br>**ប្រភពផ្ទៀងផ្ទាត់** : របាយការណ៍ប្រចាំឆ្នាំ | |
|---|---|---|---|
| **ទិន្នផលរំពឹងទុក** | **សកម្មភាព** | **សូចនាករលទ្ធផល** | **ប្រភពផ្ទៀងផ្ទាត់** |
| **៤.១.១** : រចនាសម្ព័ន្ធ ក.ជ.ក. មាន ៤ អនុគណៈកម្មការ ដែលត្រូវរៀបចំកំណែទម្រង់។ | **៤.១.១.១**: បង្កើតអនុគណៈកម្មការពិគ្រោះយោបល់ និងកៀរគរធនធាន អនុគណៈកម្មការពិនិត្យតាមដាននិងវាយតម្លៃ និងរបាយការណ៍ អនុគណៈកម្មការច្បាប់និងគោលនយោបាយ និងរក្សាអនុគណៈកម្មការពលកម្មកុមារនិង ទម្រង់ផ្សេងៗទៀតនៃការកេងប្រវ័ញ្ចលើកុមារ។ | អនុគណៈកម្មការបានដំណើរការ ដោយមានកិច្ចប្រជុំជាទៀងទាត់ និងការរៀបចំផែនការសកម្មភាព និងយុទ្ធសាស្ត្រអាទិភាព | របាយការណ៍<br>អនុគណៈកម្មការ |
| **៤.២ : ផែនការសកម្មភាពប្រចាំឆ្នាំ និងការកៀរគរធនធាន**<br>**លទ្ធផល** : ធនធានរបស់ ក.ជ.ក. ត្រូវបានបង្កើនសម្រាប់សកម្មភាពអាទិភាពរបស់ ក.ជ.ក. | | **សូនាករលទ្ធផល** : ប្រភពធនធានត្រូវបានបង្កើន ដោយផ្អែកតាមចំណុចអាទិភាពរបស់ ក.ជ.ក.<br>**ប្រភពផ្ទៀងផ្ទាត់** : របាយការណ៍ប្រចាំឆ្នាំ | |
| **ទិន្នផលរំពឹងទុក** | **សកម្មភាព** | **សូចនាករលទ្ធផល** | **ប្រភពផ្ទៀងផ្ទាត់** |
| **៤.២.១** : ក.ជ.ក. មានផែនការសកម្មភាពប្រចាំឆ្នាំ រួមជាមួយនឹងធនធាន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ | **៤.២.១.១** : បង្កើតផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់ថ្នាក់ជាតិ និងក្រោមជាតិ ដែលមានសកម្មភាពអាទិភាពដោយភ្ជាប់ជាមួយនឹងប្រភពធនធាន និងបែងចែកថវិកាដល់ ក.ជ.ក. រាជធានី ខេត្ត សម្រាប់កិច្ចប្រជុំ និងការប្រមូលរបាយការណ៍។<br>**៤.២.១.២** : វាយតម្លៃ ក.ជ.ក. នៅថ្នាក់ក្រោមជាតិ ដោយមធ្យោបាយល្អបំផុត ដើម្បីអនុវត្តអាណត្តិរបស់ខ្លួន ដោយមានផែនការសកម្មភាពច្បាស់លាស់។<br>**៤.២.១.៣**: ផ្តល់ការណែនាំផ្នែកបច្ចេកទេសបន្ថែមទៀតដល់ ក.ជ.ក. នៅថ្នាក់ក្រោមជាតិទៅលើតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។<br>**៤.២.១.៤** : រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពទៅលើសកម្មភាព និងលទ្ធផល។ | ចំនួនផែនការសកម្មភាពប្រចាំឆ្នាំដែលបានរៀបចំ<br>ចំនួន ក.ជ.ក. ថ្នាក់ក្រោមជាតិមានសមត្ថភាពអនុវត្តសកម្មភាពដោយឯកឯង<br>ចំនួនរបាយការណ៍ប្រចាំឆ្នាំ | ផែនការសកម្មភាព<br>របាយការណ៍ប្រចាំឆ្នាំ<br>របាយការណ៍ ក.ជ.ក. រាជធានី ខេត្ត |

| | | | |
|---|---|---|---|
| **៤.២.២**: ក.ជ.ក. មានយុទ្ធសាស្ត្រកៀរគរធនធាន។ | **៤.២.២.១ :** បង្កើត និងអនុវត្តយុទ្ធសាស្ត្រកៀរគរធនធានប្រចាំឆ្នាំ ដើម្បីសម្រេចបានភារកិច្ចជាក់លាក់ ដែលបានកំណត់នៅក្នុងផែនការសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក. និង ក.ជ.ក. រាជធានី ខេត្ត។<br>**៤.២.២.២** : បង្កើត និងផ្តល់ឱកាសសម្រាប់ដៃគូសាធារណៈ និងឯកជនដើម្បីជំរុញការអនុវត្តសិទ្ធិកុមារក្នុងគោលដៅយុទ្ធសាស្ត្រ។ | ចំនួនម្ចាស់ជំនួយ ប្រភពធនធានបន្ថែមដែលទទួលបាន<br>ភាគរយសកម្មភាពដែលមានមូលនិធិ<br>ចំនួនដៃគូសាធារណៈនិងឯកជន បានបង្កើតដោយមានឧស្សាហកម្ម ឬ ពាណិជ្ជកម្ម | ថវិកាប្រចាំឆ្នាំរបស់ ក.ជ.ក.<br>ផែនការសកម្មភាពរបស់ ក.ជ.ក.<br>របាយការប្រចាំឆ្នាំរបស់ ក.ជ.ក. |
| **៤.៣ : មន្ត្រី**<br>**លទ្ធផល :** មន្ត្រី ក.ជ.ក. មានសមត្ថភាពអនុវត្តតួនាទី និងការទទួលខុសត្រូវ។ | | **សូនាករលទ្ធផល :** បានបង្កើនសមត្ថភាពផ្នែកនីមួយៗ ដើម្បីអនុវត្តភារកិច្ចរបស់ពួកគេ<br>**ប្រភពផ្ទៀងផ្ទាត់ :** របាយការណ៍បញ្ចប់សកម្មភាព | |
| **ទិន្នផលរំពឹងទុក** | **សកម្មភាព** | **សូចនាករលទ្ធផល** | **ប្រភពផ្ទៀងផ្ទាត់** |
| **៤.៣.១ :** មន្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានពង្រឹងសមត្ថភាពស្តីពីសិទ្ធិកុមារ ដើម្បីមានការទទួលខុសត្រូវក្នុងការបំពេញតួនាទីរបស់ខ្លួន។ | **៤.៣.១.១**: កំណត់ពីលក្ខខណ្ឌការងារ និងរៀបចំផែនការកសាងសមត្ថភាពរបស់មន្ត្រីទាំងអស់ ផ្អែកតាមតម្រូវការនៃការទទួលខុសត្រូវរបស់មន្ត្រីនីមួយៗ។<br>**៤.៣.១.២** : រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល ដើម្បីបណ្តុះបណ្តាលដល់ថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់សៀវភៅសិក្សាស្តីពីសិទ្ធិកុមារ។<br>**៤.៣.១.៣**: រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារកម្រិតខ្ពស់ដល់មន្ត្រីបច្ចេកទេស និងមន្ត្រីច្បាប់របស់ ក.ជ.ក. ស្តីពី (១) ការពិនិត្យតាមដាន និងការធ្វើរបាយការណ៍អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែមនានានៅថ្នាក់ជាតិ និងក្រោមជាតិ (២)ការធ្វើរបាយការណ៍តាមកាលកំណត់ នៃការវិភាគស្ថានភាពសិទ្ធិកុមារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និង(៣)ការរៀបចំច្បាប់ និងគោលនយោបាយ<br>**៤.៣.១.៤**: បង្កើនសមត្ថភាពមន្ត្រីក្នុងការប្រើប្រាស់មូលដ្ឋានទិន្នន័យជាតិពាក់ព័ន្ធរួមមាន មូលដ្ឋានទិន្នន័យឃុំ សង្កាត់ ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ ស្ថិតិសុខភាពជាតិ មូលដ្ឋានទិន្នន័យ អត្តសញ្ញាណកម្មក្រីក្រ ស្ថិតិរបស់ក្រសួងផែនការ អង្កេត | លក្ខខណ្ឌការងារបានធ្វើបច្ចុប្បន្នកម្ម និងមានផែនការកសាងសមត្ថភាពសម្រាប់មន្ត្រីនីមួយៗ<br>ចំនួនវគ្គបណ្តុះបណ្តាលបានបញ្ចប់<br>ទីប្រឹក្សាបច្ចេកទេសបានផ្តល់សម្រាប់វិស័យសមត្ថភាពជាក់លាក់<br>លទ្ធផលសកម្មភាពបានបញ្ចប់ ដោយទទួលបានពីផ្នែកនីមួយៗ | របាយការណ៍បណ្តុះបណ្តាល<br>របាយការណ៍ប្រចាំឆ្នាំ |

| | | | |
|---|---|---|---|
| | ប្រជាសាស្ត្រ និងសុខភាពកម្ពុជា។<br>**៤.៣.១.៥** : បង្កើនសមត្ថភាពមន្ត្រីដើម្បីបង្កើត និងអនុវត្តយុទ្ធសាស្ត្រកៀរគរធនធាន និងការសរសេរសំណើនិងការសរសេររបាយការណ៍កម្រិតមូលដ្ឋាន និងកម្រិតវិជ្ជាជីវៈ។<br>**៤.៣.១.៦**: បង្កើនជំនាញភាសាអង់គ្លេសមន្ត្រី និងព័ត៌មានវិទ្យា។<br>**៤.៣.១.៧**: វាយតម្លៃពីរបៀបរៀបចំបន្ទុកការងារឡើងវិញ ដូច្នេះសកម្មភាព ត្រូវបានផ្តល់ជូនដល់មន្ត្រីកាន់តែច្រើន។<br>**៤.៣.១.៨**: អគ្គលេខាធិការដ្ឋាន ក.ជ.ក. ធ្វើទស្សនកិច្ចសិក្សាទៅប្រទេសពាក់ព័ន្ធ ដើម្បីសិក្សាពីគំរូនៃការពិនិត្យតាមដាននិងវាយតម្លៃដែលមានប្រសិទ្ធភាព។ | | |
| **៤.៣.២** : មានផែនការដឹកនាំក្នុងការកំណត់អំពីតម្រូវការជំនាញដឹកនាំ ដើម្បីលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ។ | **៤.៣.២.១** :វាយតម្លៃពីជំនាញដឹកនាំចាំបាច់សម្រាប់ ក.ជ.ក. ដើម្បីអនុវត្តសកម្មភាពរបស់ខ្លួន។<br>**៤.៣.២.២** : ស្វែងរកការគាំទ្រ និងជ្រើសរើសមន្ត្រី ដែលមានជំនាញតាមតម្រូវការ។ | ចំនួនមន្ត្រីថ្មីដែលមានជំនាញបានបម្រើការ<br>ឱនភាព | របាយការណ៍ប្រចាំឆ្នាំ |

## ឯកសារដែលបានដកស្រង់

- ក្រសួងសុខាភិបាល (២០១៣)។ របាយការណ៍ស្តីពីលទ្ធផលសម្រេចបានរបស់ក្រសួងសុខាភិបាល ឆ្នាំ ២០១២ និងទិសដៅ ឆ្នាំ២០១៣។ រាជធានីភ្នំពេញ។
- របាយការណ៍វឌ្ឍភាពប្រចាំឆ្នាំ២០១៣ ស្តីពីការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ក្រសួងផែនការ ឆ្នាំ២០១៤
- ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ២០១៣)។ លទ្ធផលបូកសរុបសកម្មភាពវិស័យអប់រំ យុវជន និង កីឡា ឆ្នាំ២០១២-២០១៣ និងទិសដៅ ២០១២-២០១៣។ រាជធានីភ្នំពេញ។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ឆ្នាំ២០១៣)។ លទ្ធផលការងារ ឆ្នាំ២០១២ និងទិសដៅរបស់នាយកដ្ឋានការងារកុមារ។ រាជធានីភ្នំពេញ។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ឆ្នាំ២០១៣)។ របាយការណ៍លទ្ធផលសម្រេចបាន ឆ្នាំ២០១២។ រាជធានីភ្នំពេញ។
- អង្កេតចន្លោះជំរឿន នៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ។
- អាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍ (ឆ្នាំ២០១២)។ របាយការណ៍វឌ្ឍនភាពរបស់កម្ពុជា។ រាជធានី ភ្នំពេញ។ អាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍
- កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ (ឆ្នាំ២០១១)។ របាយការណ៍វឌ្ឍនភាពគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ រាជធានីភ្នំពេញ៖
- កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ។
- យូនីសេហ្វកម្ពុជា ឆ្នាំ២០១៣។ ដកស្រង់ចេញពីស្ថិតិ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣៖ http://www.unicef.org/infobycountry/cambodia_statistics.html

## ឧបសម្ព័ន្ធ ក សមាជិកភាព រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច

## សមាជិកភាព

ក.ជ.ក មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| • **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** | ១រូប | ប្រធានកិត្តិយស |
| • រដ្ឋមន្ត្រីក្រសួងស.អ.យ | ១រូប | ប្រធាន |
| • រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ១រូប | អនុប្រធាន |
| • រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១រូប | អនុប្រធាន |
| • រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១រូប | អនុប្រធាន |
| • រដ្ឋលេខាធិការក្រសួងសុខាភិបាល | ១រូប | អនុប្រធាន |
| • រដ្ឋលេខាធិការក្រសួង ស.អ.យ | ១រូប | អនុប្រធាន |
| • រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប | អនុប្រធាន |
| • អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| • អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | ១រូប | សមាជិក |
| • អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ១រូប | សមាជិក |
| • អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| • អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ១រូប | សមាជិក |
| • អនុរដ្ឋលេខាធិការក្រសួងផែនការ | ១រូប | សមាជិក |
| • អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ១រូប | សមាជិក |
| • អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ១រូប | សមាជិក |
| • អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១រូប | សមាជិក |
| • អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ១រូប | សមាជិក |
| • អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | ១រូប | សមាជិក |
| • អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១រូប | សមាជិក |
| • អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ១រូប | សមាជិក |
| • អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ១រូប | សមាជិក |
| • អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | ១រូប | សមាជិក |
| • អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ១រូប | សមាជិក |
| • តំណាងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | ១រូប | សមាជិក |
| • តំណាងសមាគមជាតិកាកបាទក្រហមកម្ពុជា | ១រូប | សមាជិក |
| • តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | ១រូប | សមាជិក |
| • តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | ១រូប | សមាជិក |
| • អគ្គលេខាធិការ ក.ជ.ក | ១រូប | សមាជិកអចិន្ត្រៃយ៍ |

**រចនាសម្ព័ន្ធរបស់ ក.ជ.ក.**

អគ្គលេខាធិការដ្ឋាន ក.ជ.ក. មានរចនាសម្ព័ន្ធដូចខាងក្រោម៖

១. ផ្នែកផែនការ រដ្ឋបាល និងហិរញ្ញវត្ថុ

២. ផ្នែកការការពារកុមារ និងពិនិត្យតាមដាន

៣. ផ្នែកអប់រំ ផ្សព្វផ្សាយ និងអភិវឌ្ឍន៍ធនធានមនុស្ស

ផ្នែកនីមួយៗដឹកនាំដោយប្រធានផ្នែកមួយរូប អមដោយអនុប្រធានផ្នែកមួយចំនួនជាជំនួយការ តាមការចាំបាច់។

**តួនាទី និងភារកិច្ចរបស់ ក.ជ.ក.**

**ក.ជ.ក មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖**

- ពិគ្រោះយោបល់ សម្របសម្រួលសកម្មភាពទាំងឡាយណា ដែលពាក់ព័ន្ធនឹងបញ្ហាកុមារ
- ពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ កម្មវិធីជាតិសម្រាប់កុមារនៅកម្ពុជា និងលើកសំណើជូនរាជរដ្ឋាភិបាលអំពីតម្រូវការនិងបញ្ហាទាំងឡាយដែលធានាឧត្តមប្រយោជន៍របស់កុមារ
- ចូលរួមពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងកុមារ និងផ្តល់អនុសាសន៍ស្របនឹងអនុសញ្ញា និងបទដ្ឋានអន្តរជាតិផ្សេងៗស្តីពីកុមារ
- ធ្វើការផ្សព្វផ្សាយច្បាប់ អនុសញ្ញាស្តីពីសិទ្ធិកុមារ គោលនយោបាយ និងលិខិតបទដ្ឋាននានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងបញ្ហានានារបស់កុមារ និងបំផុសចលនាគាំទ្រការអនុវត្តសិទ្ធិកុមារឲ្យមានប្រសិទ្ធភាព
- រៀបចំគោលនយោបាយ ផែនការ កម្មវិធី និងសកម្មភាពផ្សេងៗ ដើម្បីឧត្តមប្រយោជន៍ដល់កុមារមានជាអាទិ៍ ការគោរព និងការអនុវត្តសិទ្ធិកុមារ រស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព ការចូលរួមចំណែករបស់កុមារ ការប្រឆាំងនឹងអំពើហិង្សា ការទប់ស្កាត់ ការលុបបំបាត់ការកេងប្រវ័ញ្ចគ្រប់រូបភាពមកលើកុមារ និងការប្រឆាំងនឹងការជួញដូរគ្រឿងញៀន
- ធ្វើទំនាក់ទំនងជាមួយសហគមន៍ជាតិ និងអន្តរជាតិ ដែលមានការងារប្រហាក់ប្រហែលគ្នា ដើម្បីរកជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ និងទស្សនៈរីកចម្រើន ដែលទាក់ទងនឹងគោលដៅរួមក្នុងការកែលម្អស្ថានភាពកុមារ
- ស្រាវជ្រាវ និងជូនព័ត៌មានស្តីពីតម្រូវការ និងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងកុមារកម្ពុជាជូនរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គការនានាដែលមានសមត្ថកិច្ច
- ពិនិត្យ និងសម្រេចបទបញ្ជាផ្ទៃក្នុងរបស់ ក.ជ.ក.
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិ ដែលពាក់ព័ន្ធនឹងសិទ្ធិរបស់កុមារ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក.**

**អគ្គលេខាធិការដ្ឋាន ក.ជ.ក. មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖**

- រៀបចំ និងអនុវត្តផែនការសកម្មភាពការងារពាក់ព័ន្ធនឹងកុមារ រយៈពេលខ្លី មធ្យម និងវែង

- សម្របសម្រួលជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារពិធីសារនានាដែលពាក់ព័ន្ធនឹងកុមារ និងកម្មវិធីជាតិដាក់ជូន ក.ជ.ក.
- ពិនិត្យស្ថានភាពរបស់កុមារ និងផ្តល់អនុសាសន៍ដោយផ្អែកលើគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ
- ជំរុញការផ្សព្វផ្សាយខ្លឹមសារអនុសញ្ញាស្តីពីសិទ្ធិកុមារឲ្យបានទូលំទូលាយរហូតដល់ថ្នាក់ក្រោមជាតិ
- សិក្សាស្រាវជ្រាវច្បាប់ជាតិ អន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកុមារ ដើម្បីតាមដាន វាយតម្លៃ និងលើកអនុសាសន៍ជូន ក.ជ.ក.
- ធ្វើសហប្រតិបត្តិការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងកុមារ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ ដើម្បីលើកអនុសាសន៍ជូន ក.ជ.ក. ដើម្បីសម្រេច និងធ្វើជូនរាជរដ្ឋាភិបាល
- ធានានិរន្តរភាព និងដំណើរការរដ្ឋបាលរបស់ ក.ជ.ក.
- គ្រប់គ្រងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន ក.ជ.ក.
- លើកសំណើតែងតាំង ផ្ទេរភារកិច្ច បញ្ឈប់ពីតំណែង និងជ្រើសរើសមន្ត្រីរាជការដែលមានក្របខណ្ឌស្រាប់ និងមន្ត្រីជាប់កិច្ចសន្យាក្នុងអគ្គលេខាធិការដ្ឋានជូនប្រធាន ក.ជ.ក.
- លើកគម្រោងថវិកាប្រចាំឆ្នាំសម្រាប់កិច្ចដំណើរការ ក.ជ.ក.
- គ្រប់គ្រងថវិកា និងធ្វើឲ្យបញ្ជីសារពើភណ្ឌចលនទ្រព្យ និងអចលនទ្រព្យរបស់ ក.ជ.ក.
- រៀបចំសិក្ខាសាលា និងកិច្ចប្រជុំផ្សេងៗរបស់ ក.ជ.ក.
- ចងក្រងព័ត៌មាន និងឯកសារទាំងអស់ដែលពាក់ព័ន្ធនឹងកុមារ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពការងាររបស់ ក.ជ.ក.
- បំពេញភារកិច្ចផ្សេងៗទៀត ប្រធាន ក.ជ.ក. ប្រគល់ជូន

## ឧបសម្ព័ន្ធ ខ ការវិភាគចំណុចខ្លាំង បញ្ហាប្រឈម ឱកាស និងឧបសគ្គ

| ការវិភាគចំណុចខ្លាំង បញ្ហាប្រឈម ឱកាស និងឧបសគ្គ | |
|---|---|
| **ចំណុចខ្លាំង** | **បញ្ហាប្រឈម** |
| - ក.ជ.ក. បានអនុវត្តដោយជោគជ័យផ្នែកដ៏សំខាន់នៃផែនការយុទ្ធសាស្ត្រ ២០១១-២០១៣ តាមរយៈការរៀបចំ និងអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំដោយផ្អែកលើយុទ្ធសាស្ត្ររបស់ខ្លួន។ ជាលទ្ធផលនៃការអនុវត្តសកម្មភាពទាំងនេះ ក.ជ.ក. មានវឌ្ឍនភាពឆ្ពោះទៅកាន់គោលដៅរបស់ខ្លួន ដែលសិទ្ធិកុមារកំពុងត្រូវបានអនុវត្តយ៉ាងពេញលេញ<br>- ក.ជ.ក. មានរចនាសម្ព័ន្ធ ដែលបានបញ្ជាក់យ៉ាងច្បាស់ និងមានរហូតដល់ថ្នាក់រាជធានី ខេត្ត<br>- អគ្គលេខាធិការដ្ឋាន ក.ជ.ក. មានក្រុមការងារដែលមានសមត្ថភាពកាន់តែរឹងមាំ ជាមួយនឹងការបង្កើនសមត្ថភាព និងតួនាទី និងការទទួលខុសត្រូវច្បាស់លាស់សម្រាប់សមាសជិក ក.ជ.ក. ម្នាក់ៗ<br>- ក.ជ.ក. មានទំនាក់ទំនងជិតស្និទ្ធជាមួយក្រសួង ស្ថាប័ននានា រួមមាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងយុត្តិធម៌ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងទេសចរណ៍ វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងស្ថាប័នផ្សេងៗទៀត និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារលើសិទ្ធិកុមារ<br>- ក.ជ.ក. បានបញ្ចប់ការប៉ាន់ប្រមាណ ការវិភាគ និងការធ្វើផែនការសកម្មភាពដែលជាមូលដ្ឋានគ្រឹះ សម្រាប់ការងារនាពេលអនាគត ដែលរួមមាន៖<br>• ការវិភាគមុខងារភារកិច្ច<br>• ការសិក្សាថវិកាសម្រាប់សង្គម<br>• សេចក្តីណែនាំស្តីពីការចូលរួមរបស់កុមារ<br>• សៀវភៅសិក្សាស្តីពីសិទ្ធិកុមារ<br>• ផែនទីបង្ហាញផ្លូវសម្រាប់ការរៀបចំផែនការសកម្មភាពជាតិ<br>• សូចនាករសំខាន់ៗសម្រាប់ការតាមដានការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ<br>• ផែនទីក្រុមការងារ និងទិន្នន័យមូលដ្ឋានស្តីពីសិទ្ធិកុមារ<br>• ការវិភាគភាពខ្វះចន្លោះនៃច្បាប់ពាក់ព័ន្ធនឹង | - ក.ជ.ក. បានអនុវត្តផ្នែកសំខាន់ៗនៃសកម្មភាពដែលបានគ្រោងទុកក្នុងផែនការយុទ្ធសាស្ត្រ ២០១១-២០១៣ និងបានរៀបចំរបាយការណ៍សកម្មភាពប្រចាំឆ្នាំ ប៉ុន្តែរបាយការណ៍ប្រចាំឆ្នាំ ពុំទាន់បានឆ្លើយតបទៅនឹងសូចនាករដូចដែលបានកំណត់<br>- ក.ជ.ក. មិនទាន់មានប្រព័ន្ធការងារពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ការប្រមូល និងគ្រប់គ្រងទិន្នន័យ ដែលប្រការនេះធ្វើឲ្យសមត្ថភាពក្នុងការពិនិត្យតាមដានស្ថានភាពសិទ្ធិកុមារក្នុងប្រទេសកម្ពុជានៅមានកម្រិតនៅឡើយ<br>- ក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ន និង ក.ជ.ក. រាជធានី ខេត្ត មិនមានថវិកាជាតិសម្រាប់បម្រើឲ្យសកម្មភាព ដូចដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ<br>- ទាមទារឲ្យមានការអភិវឌ្ឍន៍សមត្ថភាពជំនាញបន្ថែមទាក់ទងនឹងច្បាប់ ព័ត៌មានវិទ្យា ការពិនិត្យតាមដាន និងវាយតម្លៃ នីតិវិធីនៃការសរសេររបាយការណ៍ក្នុងទម្រង់ជាតិ អន្តរជាតិ ជាភាសាខ្មែរនិងអង់គ្លេស និងជំនាញគ្រប់គ្រងនិងទំនាក់ទំនង<br>- ក.ជ.ក.ថ្នាក់រាជធានី ខេត្ត មិនទាន់យល់ច្បាស់លាស់ពីតួនាទីភារកិច្ចរបស់ខ្លួនដើម្បីធានាការគាំទ្រ និងការសហការពីអាជ្ញាធរថ្នាក់ក្រោមជាតិ និងដើម្បីអនុវត្តការងារទៅតាមអាណត្តិ របស់ ក.ជ.ក.។ |

| | |
|---|---|
| ការការពារកុមារ<br>• កម្រងឯកសារច្បាប់ និងគោលនយោបាយដែលពាក់ព័ន្ធនឹងកុមារ | |
| **ឱកាស** | **ឧបសគ្គ** |
| - សកម្មភាពនៃការប៉ាន់ប្រមាណ ការវិភាគ និងការកសាងផែនការត្រូវបានបញ្ចប់ដែលជាលទ្ធផល នៃផែនការយុទ្ធសាស្ត្រ ២០១១-២០១៣ ដែលផ្តល់នូវមូលដ្ឋានគ្រឹះ និងឧបករណ៍សម្រាប់សកម្មភាព ជាយុទ្ធសាស្ត្រដែលទទួលបានជោគជ័យនៅក្នុងឆ្នាំ ២០១៤-២០១៨<br>- អនុវត្តអនុសាសន៍ពីតាមលំដាប់ពីការវិភាគ ភារកិច្ចមុខងារ<br>- លើសពីនេះទៀត បញ្ជាក់ឲ្យបានច្បាស់ពីរចនាសម្ព័ន្ធ និងការផ្តល់នូវធនធាន ដើម្បីអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ ក.ជ.ក. នៅថ្នាក់ក្រោម ជាតិ (រួមទាំងការលើកកម្ពស់ការសហការ ជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និងក្រុមការងារពហុវិស័យស្តីពីកុមារកំព្រា និងកុមាររងាយរងគ្រោះថ្នាក់ខេត្ត)<br>- រៀបចំផែនការទាក់ទាញមតិគាំទ្រ ដើម្បីថវិកាសម្រាប់កុមារ<br>- បន្តការកសាងសមត្ថភាពដល់មន្ត្រី ក.ជ.ក. នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងបណ្តុះបណ្តាលនៅនឹងកន្លែង ដោយផ្អែកលើការងារដែលទទួលខុសត្រូវ<br>- បន្តលើកកម្ពស់ការយល់ដឹងទូទៅ នៃកិច្ចខិតខំប្រឹងប្រែងចំពោះសេចក្តីសង្កេតចុងក្រោយ របស់គណៈកម្មាធិការសិទ្ធិកុមារ នៃ អ.ស.ប និងលើកកម្ពស់ការយល់ដឹងពីសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារ នៃ អ.ស.ប ទៅដល់មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាល<br>- បន្តរៀបចំព្រឹត្តបត្រស្ថានភាពកុមារ គេហទំព័រ និងរៀបចំការវិភាគស្ថានភាពកុមារប្រចាំឆ្នាំ<br>- បញ្ចប់សូចនាករសិទ្ធិកុមារ ដើម្បីវាយតម្លៃ និងតាមដានស្ថានភាពនៃសិទ្ធិកុមារ<br>- ប៉ាន់ប្រមាណពីស្ថានភាពសូចនាករសិទ្ធិកុមារ មូលដ្ឋានទិន្នន័យ និងរៀបចំផែនការដើម្បីឆ្ពោះទៅមុខ<br>- ប្រើប្រាស់ផែនទីបង្ហាញផ្លូវសម្រាប់រៀបចំផែនការជាតិសម្រាប់កុមារ ដោយរួមបញ្ចូលផែនការតាមវិស័យ ទាំងអស់ និងស្របតាមចំណុចអាទិភាពជាតិ | - មិនទាន់មានប្រភពធនធានពីខាងក្រៅ សម្រាប់យុទ្ធសាស្ត្រអាទិភាពទាំងអស់របស់ ក.ជ.ក.<br>- ភាពសុខដុមនីយកម្មអាណត្តិ តួនាទី និងការទទួលខុសត្រូវរបស់ ក.ជ.ក. ជាមួយនឹងគណៈកម្មាធិការ និងរចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាលផ្សេងៗទៀតនៅមានកម្រិតនៅឡើយ។<br>- |

| | |
|---|---|
| - ដោយផ្អែកលើការវិភាគពីភាពខ្វះចន្លោះ នៃច្បាប់ស្តីពីការការពារកុមារ និងធាតុចូលដទៃទៀត រៀបចំយុទ្ធសាស្ត្រទាក់ទាញមតិគាំទ្រសម្រាប់គោលនយោបាយ និងច្បាប់ពាក់ព័ន្ធនឹងការការពារកុមារ<br>- បន្តលើកកម្ពស់តួនាទីរបស់ ក.ជ.ក. ក្នុងកិច្ចសហការជាមួយ និងរួមចំណែកដល់ការលើកកម្ពស់សិទ្ធិកុមារតាមរយៈរចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។ | |